ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សលើលទ្ធផល

# រៀនសូត្រនៅមធ្យមសិក្សាទុតិយភូមិ

# (ករណីសិក្សានៅខេត្តត្បូងឃ្មុំ)

# THE INFLUENCES OF STUDY HABIT ON LEARNING ACHIEVEMENT AT UPPER SECONDARY LEVEL: A CASE STUDY IN TBOUNG KHMUM PROVINCE

**សន សីហា**

SAN SEYHA

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្ដុះបណ្ដាល**

**ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០២០-២០២២**

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សលើលទ្ធផល
# រៀនសូត្រនៅមធ្យមសិក្សាទុតិយភូមិ
# ( ករណីសិក្សាខេត្តត្បូងឃ្មុំ )

# THE INFLUENCES OF STUDY HABIT ON LEARNING ACHIEVEMENT AT UPPER SECONDARY LEVEL: A CASE STUDY IN TBOUNG KHMUM PROVINCE

សន សីហា

SAN SEYHA

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល

ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២០-២០២២

គ្រូណែនាំគោល៖ បណ្ឌិត នី រដ្ឋា

គ្រូណែនាំរង៖ លោក គឹម លាង

# សេចក្តីអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា «**ឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សលើលទ្ធផលរៀនសូត្រនៅមធ្យមសិក្សាទុតិយភូមិ (ករណីសិក្សាខេត្តត្បូងឃ្មុំ)**» សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ពិតជាស្នាដៃរបស់ខ្ញុំបាទ ទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជាត្រូវបានស្រាវជ្រាវនិងចងក្រងដោយខ្ញុំបាទពិតប្រាកដមែន។

ថ្ងៃ អាទិត្យ១៣កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២២

**ហត្ថលេខា**

**សន សីហា**

# លិខិតបញ្ជាក់

**បណ្ឌិត នី រដ្ឋា** ជាគ្រូណែនាំគោល

**លោក គឹម លាង** ជាគ្រូណែនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **សន សីហា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ ពិតជាបានសរសេរ និក្ខេបបទស្រាវជ្រាវស្តីពី «**ឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សលើលទ្ធផលរៀនសូត្រនៅមធ្យមសិក្សាទុតិយភូមិ** (**ករណីសិក្សាខេត្តត្បូងឃ្មុំ**) » ពិតប្រាកដមែន។

ថ្ងៃ អាទិត្យ១៣កើត ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០២២

| | |
|---|---|
| ...................................... | ...................................... |
| **បណ្ឌិត នី រដ្ឋា** | **លោក គឹម លាង** |
| ប្រធានការិយាល័យសិក្សា | អនុប្រធានដេប៉ាតឺម៉ង់ |
| វិទ្យាស្ថានជាតិអប់រំ | វិទ្យាស្ថានជាតិអប់រំ |

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៣៧០២៥ អយក.ឧទន

(ការសម្ងាត់)

## លិខិតឧទ្ទេសនាម

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងទី១០ ឆ្នាំ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំង ជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ ទី៩ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ជួន ណារ៉ុន | ឧទ្ទកាល័យ អយក | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិតសភាចារ្យ | ណាត ប៊ុនរឿន | ឧទ្ទកាល័យ អយក | អនុប្រធាន |
| ៣-ឯកឧត្តម | យក់ ង៉ុយ | ឧទ្ទកាល័យ អយក | សមាជិក |
| ៤-ឯកឧត្តម | លាង សេងហាក់ | ឧទ្ទកាល័យ អយក | សមាជិក |
| ៥-ឯកឧត្តម | ម៉ក់ ង៉យ | អគ្គនាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | សមាជិក |
| ៧-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-ឯកឧត្តមបណ្ឌិត | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ១០-ឯកឧត្តមបណ្ឌិត | សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១១-លោកបណ្ឌិត | ឈុក ច័ន្ទធាយា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកបណ្ឌិត | នូវ វ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | ហេង គ្រេង | នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ | សមាជិក |
| ១៥-លោកស្រីបណ្ឌិត | បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១៦-លោកបណ្ឌិត | អែ សុងហ៊ាង | SEAMEO TED អយក | សមាជិក |
| ១៧-លោកបណ្ឌិត | មាឃ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ១៨-លោកបណ្ឌិត | ឈិញ ស៊ីថា | អ្នកឯកទេសអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | នី វង្ហា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១-លោកបណ្ឌិត | ឈាង សង្ខាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២២-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣-លោក | ចាប តេនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២២ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៧កើត ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០២២
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

កន្លែងទទួល៖
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាព ពាក់ព័ន្ធក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ វជអ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ...៣៧២៦...អយក.ប្រក

(ការសម្ងាត់)

## លិខិតឧទ្ទេសនាម

យោងៈ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងទី១០ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំៈ

| | | | |
|---|---|---|---|
| ១-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣-លោកបណ្ឌិត | អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤-លោកបណ្ឌិត | ឡាយ សុវិជ្ជា | នាយកដ្ឋានគោលនយោបាយ | សមាជិក |
| ៥-លោកបណ្ឌិត | សោន វណ្ណៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកបណ្ឌិត | ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោកបណ្ឌិត | លី គឹមឡុង | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៨-លោកបណ្ឌិត | ឈិញ នីដា | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៩-លោកបណ្ឌិត | អ៊ុំ ចាន់ចំណាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោកបណ្ឌិត | កាង ស៊ុងឆាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោក | ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោក | លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោក | ចាន់ រ៉ាដា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | មឿន លិនណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោកបណ្ឌិត | គួយ សុគាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦-លោកស្រីបណ្ឌិត | ឡឹយ សុគា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧-លោក | ប៉ូ ប៊ុន្នល | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | សឿ សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០.លោក | ឋាច់ សន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១.លោក | ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២២.លោកស្រី | សេង សច្ចា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣.លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤.លោកស្រី | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៥.លោកស្រី | ឯម សុភាលក្ស្មី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតពីថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៧កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

កន្លែងទទួល៖

- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាព ពាក់ព័ន្ធក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ វជអ

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# សេចក្តីថ្លែងអំណរគុណ

ការសិក្សាស្រាវជ្រាវមួយនេះ សម្រេចបានដល់គោលដៅប្រកបដោយភាពជោគជ័យ ព្រោះមានការចូលរួមយ៉ាងសកម្មពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធ ដែលបានចូលរួមផ្តល់ឱកាសជួយសម្របសម្រួល និងជ្រោមជ្រែងយ៉ាងយកចិត្តទុកដាក់បំផុតតាំងពីចាប់ផ្តើមរហូតដល់ទីបញ្ចប់។ ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគណៈកម្មការវគ្គបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ និងលោកគ្រូ អ្នកគ្រូ ដែលបានឆ្លៀតពេលដ៏មមាញឹក ដើម្បីរៀបចំការបណ្តុះបណ្តាល និងបានផ្តល់នូវចំណេះជំនាញដ៏មានតម្លៃដល់រូបខ្ញុំបាទ។ ខ្ញុំបាទក៏សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះលោកបណ្ឌិត **នី រដ្ឋា** គ្រូណែនាំគោល និងលោក **គឹម លាង** គ្រូណែនាំរង ដែលបានជួយជ្រោមជ្រែង លើកទឹកចិត្ត និងផ្តល់ការណែនាំវិធីសាស្ត្រល្អៗ នៅគ្រប់ជំហាននៃការសរសេរនិក្ខេបបទស្រាវជ្រាវនេះ មិនថាពេលថ្ងៃឬពេលយប់រហូតដល់ការបញ្ចប់និក្ខេបបទនេះដោយជោគជ័យ។ ខ្ញុំបាទក៏មិនភ្លេចផងដែរ ចំពោះអំណរគុណយ៉ាងជ្រាលជ្រៅបំផុត របស់លោកឪពុក **សន ស្រ៊ាង** និង អ្នកម្តាយ**សួន សុឃា** ដែលបានផ្តល់កំណើតចិញ្ចឹមបីបាច់ថែរក្សា ផ្តល់ភាពកក់ក្តៅ ផ្តល់ដំបូន្មានឱ្យកូនធ្វើតែអំពើល្អ ឧបត្ថម្ភគាំទ្រឱ្យកូនបានសិក្សារៀនសូត្រខ្ពង់ខ្ពស់រហូតទទួលបានផ្លែផ្កាដូចបច្ចុប្បន្ន។ ការសម្រេចបានជោគជ័យនេះក៏មានចំណែករបស់អ្នកគ្រូ **ស្រស់ ដារ៉ាទី** ភរិយាខ្ញុំបាទផងដែរ។ សូមអរគុណជាអនេកចំពោះភរិយាខ្ញុំបាទ ដែលតែងតែជួយទាំងកម្លាំងកាយនិងចិត្តដល់រូបខ្ញុំបាទ និងតែងតែនៅក្បែររូបខ្ញុំបាទក្នុងគ្រាដ៏មមាញឹកនេះ។

ខ្ញុំបាទសូមអំណរគុណផងដែរចំពោះ លោកនាយក លោកគ្រូ អ្នកគ្រូជាភាគសំណាកដែលបានចូលរួមក្នុងឆ្លើយតបលើកម្រងសំណួរស្រាវជ្រាវនេះ និងអ៊ំ មា មីង បងៗ ដែលបានបង្ហាញផ្លូវជីវិត និងបានជួយជាថវិការដល់ក្មួយក្នុងការសិក្សាកន្លងមក និងមិត្តរួមជំនាន់ទី៩ ដែលបានចែករំលែកចំណេះដឹង និងបទពិសោធន៍ល្អៗ ប្រកបដោយភាតរភាពរវាងគ្នានិងគ្នា។ ជាទីបញ្ចប់ ខ្ញុំបាទសូមគោរពជូនពរចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូ និងមិត្តភក្តិរួមជំនាន់ទាំងអស់ សូមសមប្រកបតែនឹងពុទ្ធពរទាំងឡាយ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មូលន័យសង្ខេប

គោលបំណងសំខាន់នៃការសិក្សានេះគឺដើម្បីស្វែងយល់សិក្សាពី (១) ឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេនៅមធ្យមសិក្សាទុតិយភូមិ នៅខេត្តត្បូងឃ្មុំ និង (២) ប្រៀបធៀបឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេនៅមធ្យមសិក្សាទុតិយភូមិ នៅខេត្តត្បូងឃ្មុំដោយផ្អែកតាមភេទ និងកម្រិតថ្នាក់សិក្សា។

ការសិក្សានេះត្រូវបានធ្វើឡើងតាមបែបបរិមាណវិស័យ។ ភាគសំណាកសម្រាប់ការស្រាវជ្រាវនេះគឺ គ្រូបង្រៀនចំនួន ៥៥ នាក់ និងសិស្សចំនួន ១៨០ នាក់ នៅវិទ្យាល័យចំនួន ០៦នៃខេត្តត្បូងឃ្មុំ ដែលត្រូវបានជ្រើសរើសផ្អែកលើលក្ខណៈវិនិច្ឆ័យសមស្របសម្រាប់ប្រធានបទ។ ឧបករណ៍ដែលប្រើក្នុងការស្រាវជ្រាវនេះ គឺជាកម្រងសំណួរកម្រងសំណួរទម្លាប់សិក្សារបស់ Essuman's និងកែសម្រួលដោយអ្នកស្រាវជ្រាវដោយពិចារណាលើបញ្ញត្តិទ្រឹស្តី និងការស្រាវជ្រាវពាក់ព័ន្ធ។ ទិន្នន័យដែលទទួលបានពីការបំពេញកម្រងសំណួរត្រូវបានវិភាគតាមស្ថិតិបែបពណ៌នា ដោយប្រើប្រាស់កម្មវិធី IBM SPSS Statistics ។

លទ្ធផលនៃការស្រាវជ្រាវបានបង្ហាញ សូចនាករដែលឆ្លើយតបទៅលើឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់សិស្សមធ្យមសិក្សាទុតិយភូមិ នៅខេត្តត្បូងឃ្មុំ ស្ថិតនៅកម្រិតល្អ ដោយ (មធ្យម=៣.៤៦)។ ក្នុងនោះផងដែរសូចនាករនៃការអាននិងការធ្វើកំណត់ត្រា ការប្រឡង ការផ្តោតអារម្មណ៍ ស្ថិតនៅកម្រិតចង្អុលបង្ហាញល្អប្រហាក់ប្រហែលគ្នា។ មានតែការគ្រប់គ្រងពេលវេលាស្ថិតនៅកម្រិតមធ្យមនៅឡើយ។ ចំណែកឯការប្រៀបធៀបទម្លាប់សិក្សារវាងភេទ និងកម្រិតថ្នាក់រៀនសុទ្ធតែមានភាពប្រហាក់ប្រហែល។

ផ្អែកលើការរកឃើញ ភាគីពាក់ព័ន្ធទាំងអស់ក្នុងវិស័យអប់រំដូចជា ក្រសួងអប់រំ យុវជន និងកីឡា មាតាបិតា គ្រូបង្រៀនគួរតែលើកទឹកចិត្តសិស្សក្នុងផ្នែកនៃទំនួលខុសត្រូវរៀងៗខ្លួន ដូចជាការផ្តល់សម្ភារៈសិក្សា ទីកន្លែងសិក្សា ការលើកទឹកចិត្តកោតសរសើរដល់សិស្សានុសិស្សដែលខិតខំប្រឹងប្រែងឱ្យបានឆាប់។ ទាំងនេះនឹងជួយជំរុញទឹកចិត្តសិស្សឱ្យឆ្ពោះទៅរកការសិក្សាជាវិជ្ជមាន។


**ពាក្យគន្លឹះ៖** ទម្លាប់ ទម្លាប់សិក្សា លទ្ធផលសិក្សា ការគ្រប់គ្រងពេលវេលា កិច្ចការផ្ទះ ការផ្តោតអារម្មណ៍។

// Abstract

The main purpose of this study was to understand (1) the effect of study habits of students on their learning achievement at upper secondary level in Tbong Khmum province and (2) compare the effect of study habits of students on learnnig achievement. Theirs in high school in Tbong Khmum based on gender and grade level.

A quantitative research method was used in this study. The sample for this research was 55 teachers and 180 students at 6 high schools in Tbong Khmum province who were selected based on the appropriate criteria for the topic. The instrument used in this research is Essuman's Questionnaire and edited by the researchers, taking into account the theoretical and relevant research provisions. Data obtained from completing the questionnaire were analyzed by descriptive statistics using IBM SPSS Statistics.

The results of the research show that the indicators that respond to the influence of students' study habits on learning achievement at upper secondary level in Tbong Khmum are at a good level (average = 3.46). Also, the indicators of reading and taking notes, concentration, exams are at a similarly good indicator level. Only time management is still moderate. Therefore, in order to achieve good academic results, students need to develop good study habits, better time management, focus, regular homework, good preparation for exams, reading and taking notes. The comparison of study habits between male and female students is similar. Comparisons for grades 10, 11 and 12 also have similar student habits.

Based on the findings of all stakeholders in the education sector, such as the Ministry of Education, Youth and Sports, parents, teachers and should encourage students in their respective areas of responsibility, such as providing study materials, place of study, encouragement, appreciation to students who Strive as soon as possible. These will motivate students towards positive learning.

**Keywords**: Habits, Study Habits, Learning Achievement, Time Management, homework, concentration.

# មាតិកា

**ចំណងជើង** **ទំព័រ**


**សេចក្តីអះអាងរបស់បេក្ខជន** ........ i

**លិខិតបញ្ជាក់** ........ ii

**លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ** ........ iii

**សេចក្តីថ្លែងអំណរគុណ** ........ vii

**មូលន័យសង្ខេប** ........ viii

Abstract ........ ix

**ជំពូកទី១** ........ 1

**សេចក្តីផ្តើម** ........ 1

១.១- លំនាំបញ្ហា ........ 1

១.២- ចំណោទបញ្ហានៃការស្រាវជ្រាវ ........ 4

១.៣- គោលបំណងនៃការស្រាវជ្រាវ ........ 5

១.៤- សំណួរស្រាវជ្រាវ ........ 5

១.៥- សារៈសំខាន់នៃការស្រាវជ្រាវ ........ 5

១.៦- ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ 7

១.៧- រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ 7

**ជំពូកទី ២** ........ 10

**ការរំលឹកទ្រឹស្តី** ........ 10

២.១- សេចក្តីផ្តើម ........ 10

២.២- និយមន័យនៃពាក្យគន្លឹះ ........ 10

២.២.១- លក្ខណៈនៃទម្លាប់ ........ 11

២.២.២- សារៈសំខាន់នៃទម្លាប់ ........ 12
២.៣- និយមន័យទម្លាប់សិក្សា ........ 12
២.៤- ទម្លាប់សិក្សារបស់សិស្ស និងសារៈសំខាន់របស់ទម្លាប់ ........ 15
២.៤.១- ការអភិវឌ្ឍន៍ទម្លាប់សិក្សាល្អ ........ 16
២.៥- កត្តាដែលជះឥទ្ធិពលដល់ទម្លាប់សិក្សារបស់សិស្សវិទ្យាល័យ ........ 17
២.៥.១- កត្តាផ្សេងទៀតដែលមានឥទ្ធិពលលើទម្លាប់សិក្សារបស់សិស្សវិទ្យាល័យ ........ 18
២.៥.១.១- យេនឌ័រ និងទម្លាប់សិក្សារបស់សិស្ស ........ 18
២.៥.១.២- ទម្លាប់សិក្សា និងស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ឪពុកម្តាយ ........ 18
២.៦- បញ្ញត្តិនៃលទ្ធផលសិក្សា ........ 19
២.៧- កត្តាដែលជះឥទ្ធិពលលើលទ្ធផលសិក្សារបស់សិស្សវិទ្យាល័យ ........ 20
២.៧.១- កម្រិតនៃការអប់រំរបស់មាតាបិតា និងលទ្ធផលសិក្សារបស់សិស្ស ........ 22
២.៧.២- ប្រាក់ចំណូលមាតាបិតា ឬមុខរបរ និងលទ្ធផលសិក្សារបស់សិស្ស ........ 23
២.៧.៣- យេនឌ័រ និងលទ្ធផលសិក្សារបស់សិស្ស ........ 24
២.៨- ទម្លាប់សិក្សា និងលទ្ធផលសិក្សារបស់សិស្សវិទ្យាល័យ ........ 28
២.៩- ផ្នែកផ្សេងៗទៀតនៃទម្លាប់សិក្សា ........ 30
២.៩.១- កិច្ចការផ្ទះ ........ 30
២.៩.២- ការគ្រប់គ្រងពេលវេលា ........ 33
២.៩.៣- ការអាន និង ការធ្វើកំណត់ត្រា ........ 34
២.៩.៤- ការផ្តោតអារម្មណ៍ ........ 36
២.១១- សេចក្តីសង្ខេប ........ 38
**ជំពូកទី៣** ........ 40
**វិធីសាស្ត្រនៃការស្រាវជ្រាវ** ........ 40
៣.១- គម្រោងវិភាគ ........ 40

៣.២- ការប្រមូលទិន្នន័យ......40
៣.៣- ឧបករណ៍ការស្រាវជ្រាវ......41
៣.៣.១- ការបង្កើតឧបករណ៍......41
៣.៣.២- លក្ខណៈរបស់ឧបករណ៍......42
៣.៣.២.២- កម្រងសំណួរសម្រាប់គ្រូ......43
៣.៣.៣- កម្រិតចង្អុលបង្ហាញ......44
៣.៤-.ការជ្រើសរើសសំណាក......44
៣.៥- ការវិភាគទិន្នន័យ......45
**ជំពូកទី៤**......48
**លទ្ធផល និងការពិភាក្សា**......48
៤.១- ការវិភាគទិន្នន័យលើកម្រងសំណួរ ស្តីពីព័ត៌មានប្រជាសាស្ត្ររបស់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស......48
៤.១.១- ព័ត៌មានប្រជាសាស្ត្ររបស់គ្រូបង្រៀន......49
៤.១.២- ព័ត៌មានប្រជាសាស្ត្ររបស់សិស្ស......50
៤.២- ការវិភាគទិន្នន័យលើកម្រងសំណួរស្តីពីឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេនៅមធ្យមសិក្សាទុតិយភូមិ នៅខេត្តត្បូងឃ្មុំ......55
៤.២.១- ឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេនៅមធ្យមសិក្សាទុតិយភូមិ នៅខេត្តត្បូងឃ្មុំ តាមការឆ្លើយតបរបស់សិស្ស......55
៤.២.២- លទ្ធផលនៃការសិក្សាស្រាវជ្រាវលើឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេនៅមធ្យមសិក្សាទុតិយភូមិ នៅខេត្តត្បូងឃ្មុំ តាមការឆ្លើយតបរបស់សិស្ស......61
៤.២.៣- ឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេនៅមធ្យមសិក្សាទុតិយភូមិ នៅខេត្តត្បូងឃ្មុំ តាមការឆ្លើយតបរបស់គ្រូ......62

៤.៣- ការពិភាក្សាលើ ឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេនៅមធ្យមសិក្សាទុតិយភូមិ នៅខេត្តត្បូងឃ្មុំ ........ 68
៤.៤- ការវិភាគទិន្នន័យលើកម្រងសំណួរស្តីពី ការប្រៀបធៀបឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេផ្អែកតាមភេទ និងកម្រិតថ្នាក់សិក្សា ........ 71
៤.៤.១- ប្រៀបធៀបឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេផ្អែកតាមភេទ ........ 71
៤.៤.២- ប្រៀបធៀបឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេផ្អែកតាមកម្រិតថ្នាក់សិក្សា ........ 72
៤.៥- លទ្ធផលនៃការវិភាគទិន្នន័យលើកម្រងសំណួរស្តីពី ការប្រៀបធៀបឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេផ្អែកតាមភេទ និងកម្រិតថ្នាក់សិក្សា ........ 72
៤.៥.១- ប្រៀបធៀបឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេផ្អែកតាមភេទ ........ 72
៤.៥.២- ប្រៀបធៀបឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេផ្អែកតាមកម្រិតថ្នាក់ ........ 74
៤.៥.៣- ការរកឃើញចម្បង ........ 75
**ជំពូកទី៥** ........ 77
**សេចក្តីសន្និដ្ឋាន និងសំណូមពរ** ........ 77
៥.១- សេចក្តីសន្និដ្ឋាន ........ 77
៥.២- សំណូមពរ ........ 79
**ឯកសារយោង** ........ 83
**ឧបសម្ព័ន្ធ** ........ 86

# បញ្ជីតារាង

តារាងទី១៖ ទិន្នន័យចំនួនវិទ្យាល័យភាគសំណាកដែលទទួលបានពីការបំពេញកម្រងសំណួរ..........45

តារាងទី២៖ ទិន្នន័យព័ត៌មានទូទៅនៃចំនួន និងភាគរយសំណាកគ្រូបង្រៀន................................49

តារាងទី៣ ៖ អាយុសិស្ស...............................................................................................50

តារាងទី៤៖ ភេទសិស្ស...................................................................................................51

តារាងទី៥៖ កម្រិតអប់រំរបស់ឪពុកម្ដាយ..........................................................................52

តារាងទី៦៖ មុខរបរឪពុកម្ដាយ.......................................................................................53

តារាងទី៧៖ លទ្ធផលសិស្សរបស់សិស្ស……………………………………………………………...54

តារាងទី៨៖ ការគ្រប់គ្រងពេលវេលា ..............................................................................55

តារាងទី៩ ៖ការអាន និងការធ្វើកំណត់ត្រា .......................................................................57

តារាងទី១០ ៖ ការផ្ដោតអារម្មណ៍ ...................................................................................58

តារាងទី១១ ៖ កិច្ចការផ្ទះ ..............................................................................................59

តារាងទី១២៖ ការប្រឡង................................................................................................60

តារាងទី១៣៖ តារាងទិន្នន័យសរុបរបស់សិស្ស……………………………………………….........62

តារាងទី១៤៖ ការគ្រប់គ្រងពេលវេលា ............................................................................63

តារាងទី១៥៖ការអាន និងការកំណត់ត្រា ........................................................................64

តារាងទី១៦៖ ការផ្ដោតអារម្មណ៍ ....................................................................................65

តារាងទី១៧៖ កិច្ចការផ្ទះ...............................................................................................66

តារាងទី១៨៖ ការប្រឡង................................................................................................66

តារាងទី១៩៖ តារាងទិន្នន័យឆ្លើយតបសរុបរបស់គ្រូ .........................................................67

តារាងទី២០៖ តារាងទិន្នន័យឆ្លើយតបរបស់គ្រូបង្រៀន និងសិស្សានុសិស្ស..................................68

តារាងទី២១៖ ប្រៀបធៀបឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេផ្អែកតាមភេទ........................................................................................................ 71
តារាងទី២២៖ ប្រៀបធៀបឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេផ្អែកតាមកម្រិតថ្នាក់សិក្សា ........................................................................................72

# ជំពូកទី១

# សេចក្តីផ្តើម

# ជំពូកទី១

# សេចក្តីផ្តើម

## ១.១- លំនាំបញ្ហា

ចាប់ពីចុងទសវត្សរ៍ឆ្នាំ ១៩៨០ និងដើមទសវត្សរ៍ឆ្នាំ ១៩៩០ កម្ពុជាបានដាក់ចេញនូវការកែទម្រង់មូលដ្ឋានគ្រឹះសេដ្ឋកិច្ច ដោយបែរឆ្ពោះទៅរកសេដ្ឋកិច្ចទីផ្សារ និងការបើកចំហពាណិជ្ជកម្មអន្តរជាតិ។ គោលនយោបាយសេដ្ឋកិច្ចនេះ នាំមកនូវការផ្លាស់ប្តូរទាំងស្រុងនូវជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាគ្រប់ស្រទាប់វណ្ណៈ និងសម្រេចបានវឌ្ឍនភាពនៅគ្រប់វិស័យរហូតដល់បច្ចុប្បន្ន។ ក្នុងរយៈពេលជិតបីទសវត្សរ៍កន្លងមក រាជរដ្ឋាភិបាល សម្រេចបានសុខសន្តិភាពពេញលេញ បូរណភាពទឹកដី សាមគ្គីភាពជាតិ និងស្ថេរភាពនយោបាយ និងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច និងបានចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនប្រជាជនគ្រប់ស្រទាប់វណ្ណៈបានទាន់ពេលវេលា។ មូលដ្ឋានគ្រឹះដ៏រឹងមាំនេះបានជួយរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និង អភិវឌ្ឍវិស័យឯកជនឱ្យកាន់តែរស់រវើក ដែលជាប្រភពក្នុងការបង្កើនការងារ និងជាចលកប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ២០១៥។ ប្រការនេះបានកំពុងលើកទឹកចិត្តរាជរដ្ឋាភិបាលក្នុងការបង្កបង្កើនកិច្ចខំប្រឹងប្រែង សំដៅធានាជីវភាពនៃកំណើនសេដ្ឋកិច្ចកម្ពុជាប្រកបដោយចីរភាព ដោយបានដាក់ចេញនូវចក្ខុវិស័យប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០(រាជរដ្ឋាភិបាលកម្ពុជា ២០២១)។ ដើម្បីសម្រេចចក្ខុវិស័យនេះកម្ពុជាត្រូវការធនធានមនុស្សដែលមានគុណភាពខ្ពស់ សម្រាប់បង្កើតវិស័យសេដ្ឋកិច្ចថ្មីៗ ដូចជាអេឡិចត្រូនិចកសិឧស្សាហកម្មឡជីស្ទីកនៅក្នុងយុគឌីជីថល ដែលទាមទារឱ្យយុវជនកម្ពុជាមានបំណិនសតវត្សទី២១ ដោយផ្តោតលើការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា(STEM) សម្រាប់ប្រកួតប្រជែងនៅក្នុងតំបន់ និងក្រៅតំបន់(ហាង់ជួន ណារ៉ុន ២០២០)។ ក្រសួងអប់រំ យុវជន និងកីឡា មានភារកិច្ចផ្តល់ជូនប្រជាជនកម្ពុជាគ្រប់រូបនូវឱកាសនានាដែលចាំបាច់ដើម្បីឱ្យពួកគេមានគុណភាពជីវិតខ្ពស់បំផុតសម្រាប់ខ្លួនឯង និងសម្រាប់ប្រទេសកម្ពុជាទាំងមូល។ការបោះជំហានឆ្ពោះទៅរកការសម្រេចបាននូវគោលដៅនេះ ក្រសួងអប់រំបានប្តេជ្ញាក្នុងការលើកកម្ពស់គុណភាពនៃ

ការបង្រៀន និងរៀន ក៏ដូចជាគុណភាពរបស់ប្រព័ន្ធសាលារៀនឱ្យកាន់តែទូលំទូលាយជាមុន ដើម្បីជួយឱ្យសិស្សានុសិស្ស ឪពុកម្ដាយ សហគមន៍ គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀនសម្រេចបាននូវស្តង់ដាថ្នាក់ជាតិរួម។ ស្តង់ដានេះអាចសម្រេចបាន ចាំបាច់ត្រូវមានមធ្យោបាយក្នុងការវាស់វែងវឌ្ឍនភាព និងលទ្ធផលសិក្សារបស់សិស្សដែលសម្រេចបាន។ លទ្ធផលសិក្សាល្អជាធម្មតានាំមកនូវការពេញចិត្ត និងសុភមង្គលដល់បុគ្គល និងគ្រួសារទាំងមូល។ មានការស្រាវជ្រាវជាច្រើនបានបង្ហាញថា លទ្ធផលសិក្សារបស់សិស្សបានកើតឡើងពីកត្តាអន្តរកម្មដូចជា ទម្លាប់សិក្សា ភាពវៃឆ្លាតក្នុងការដោះស្រាយបញ្ហា វិធីសាស្ត្របង្រៀនរបស់គ្រូ បរិយាកាសសាលា និងអាណាព្យាបាល(Reyes, J. C.,2011)។

ដូច្នេះលទ្ធផលមិនល្អរបស់សិស្សក្នុងការប្រឡងអាច បណ្ដាលមកពីដំណើរការបង្រៀនរបស់គ្រូ ទម្លាប់សិក្សាមិនល្អរបស់សិស្ស និងបរិយាកាសសិក្សាមិនសមរម្យ។ នៅពេលដែលលទ្ធផលសិក្សាមិនល្អ សិស្សម្នាក់ៗ និងអាណាព្យាលតែងជួបប្រទះនូវបញ្ហាផ្លូវចិត្ត ដោយបារម្ភពីការសិក្សារបស់កូនទាក់ទងនឹងសាលារៀនសិស្សម្នាក់ៗសិក្សា។ ទាំងនេះហេតុផលក្នុងការបញ្ជាក់ថា ការធ្វើឱ្យប្រសើរឡើងនូវទម្លាប់ក្នុងការសិក្សាគឺជាគោលបំណងមូលដ្ឋានមួយនៃការអប់រំសិស្ស។ នៅគ្រប់សាលារៀន លទ្ធផលសិក្សាគឺជាអ្វីដែលសិស្សម្នាក់ៗខិតខំដើម្បីសម្រេចបាន ហើយការសម្រេចបាននូវលទ្ធផលល្អអាចត្រូវបានពង្រឹងតាមរយៈទម្លាប់សិក្សាល្អ។ តាមការសិក្សារបស់ Pinda (2000) បានរកឃើញថា លទ្ធផលសិក្សារបស់សិស្សត្រូវបានជះឥទ្ធិពលយ៉ាងខ្លាំងដោយទម្លាប់សិក្សារបស់ពួកគេ។ ជាពិសេស Bakare (1977) បានសង្កត់ធ្ងន់ថា ទម្លាប់សិក្សារបស់សិស្សមិនអាចត្រូវបានគេព្រងើយកន្តើយពីលទ្ធផលសិក្សារបស់ពួកគេបានទេ ព្រោះភាពជោគជ័យក្នុងការខិតខំសិក្សាគឺពឹងផ្អែកយ៉ាងធំធេងលើការអានក្នុងការស្វែងរកចំណេះដឹង និងការពិត។ Anameze (2001) បានកត់សម្គាល់ថា ចាប់តាំងពីការអប់រំត្រូវបានចាត់ទុកថាជាផ្នែកមួយយ៉ាងសំខាន់នៃការអភិវឌ្ឍន៍ជាតិ កត្តាដែលជំរុញការសិក្សា ដូចជាទម្លាប់សិក្សាប្រកបដោយប្រសិទ្ធភាពក្នុងចំណោមសិស្ស គួរតែត្រូវបានលើកទឹកចិត្ត។ ការលើកកម្ពស់ទម្លាប់សិក្សាប្រកបដោយប្រសិទ្ធភាពក្នុងចំណោមសិស្ស គួរតែមានចំណាប់អារម្មណ៍យ៉ាងខ្លាំងពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ក្នុងវិស័យអប់រំ។ ក្នុងនោះផងដែរលោក Akinboye (1980) បានយល់ឃើញថា លទ្ធផលសិក្សាជាឧបករណ៍មួយក្នុងការវាស់

វែង ទម្លាប់សិក្សាដែលសិស្សបានកំពុងសិក្សាតាមសាលារបស់ពួកគេ។ ទម្លាប់សិក្សារបស់សិស្សជាវិជ្ជមានផ្តល់កម្រិតការយល់ដឹងខ្ពស់ ខណៈពេលដែលទម្លាប់សិក្សាអវិជ្ជមានរបស់ពួកគេអាចមានការធ្វើឱ្យមានសកម្មភាពមិនល្អ និងជាលទ្ធផលនាំឱ្យដំណើរការក្នុងការសិក្សាមិនបានល្អ ក៏ដូចជាប៉ះពាល់លើការទទួលបានគិតស៊ីរបស់សិស្ស។

សូចនាករនៃទម្លាប់សិក្សាល្អក្នុងចំណោមសិស្សានុសិស្ស មានដូចជា ការកត់ត្រាមេរៀន ពេលវេលាសិក្សាគ្រប់គ្រាន់ ទីកន្លែងសម្រាប់សិក្សា ការរៀបចំកាលវិភាគសិក្សាបានច្បាស់លាស់ ការទំនុកបម្រុងរបស់អាណាព្យាបាល និងទំនួលខុសត្រូវផ្ទាល់ខ្លួនរបស់សិស្ស (Acido, 2010)។ ម្យ៉ាងវិញទៀត ទម្លាប់សិក្សាគឺជាកត្តាមួយ ដែលអាចជះឥទ្ធិពលយ៉ាងខ្លាំងដល់ការអនុវត្តលើការសិក្សារបស់សិស្ស។ ប្រសិនបើរឿងនេះមិនត្រូវបានផ្តល់ការយកចិត្តទុកដាក់ពីអ្នកពាក់ព័ន្ធទេ ឥទ្ធិពលរបស់វាអាចកាន់តែធ្វើឱ្យមានបញ្ហាដល់ដំណើរការសិក្សា របស់សិស្ស (Ebele & Olofu, 2017)។ សិស្សត្រូវមានទម្លាប់សិក្សាល្អ ដើម្បីដោះស្រាយបញ្ហាក្នុងជីវិត ព្រោះទម្លាប់សិក្សារបស់សិស្សជួយក្នុងការទទួលបានចំណេះដឹង ដែលពាក់ព័ន្ធនិងអាចអនុវត្តផ្ទាល់លើជីវិតប្រចាំថ្ងៃបាន។

ដូច្នេះការរៀបចំផែនការដ៏ម៉ឺងម៉ាត់ និងអាកប្បកិរិយាវិជ្ជមានចំពោះការសិក្សារបស់បុគ្គលម្នាក់ គួរតែត្រូវបានលើកទឹកចិត្តក្នុងចំណោមសិស្ស ដើម្បីធានាបាននូវលទ្ធផលសិក្សាល្អ។ ដើម្បីបង្កើនទម្លាប់សិក្សារបស់សិស្ស Mackeracher (1996) បានស្នើឱ្យប្រើភាពជាដៃគូក្នុងការសិក្សាការពិភាក្សាជាក្រុម និងករណីសិក្សាសម្រាប់សិស្សានុសិស្ស ដើម្បីរក្សាបាននូវគំរូនៃអាកប្បកិរិយាសិក្សាជាប់ជាប្រចាំ។

Lock (1981) មានបានលើកឡើងថា អ្នកសិក្សាគួរបង្កើនជំនាញអភិវឌ្ឍខ្លួន ជំនាញប្រតិបត្តិ និងជំនាញបញ្ចេញមតិ។ ជំនាញអភិវឌ្ឍន៍ផ្ទាល់ខ្លួន បង្ហាញពីវិន័យផ្ទាល់ខ្លួន និងជំនាញគ្រប់គ្រងល្អ ខណៈពេលដែលជំនាញដំណើរការវិធីសាស្រ្ត និងបច្ចេកទេសដែលសិស្សសម្របខ្លួននៅពេលសិក្សាដែលរួមបញ្ចូលដល់ដំណើរការគិតយ៉ាងស៊ីជម្រៅ។

## ១.២- ចំណោទបញ្ហានៃការស្រាវជ្រាវ

បច្ចុប្បន្នក្រសួងអប់រំ យុវជន និងកីឡា កំពុងយកចិត្តទុកដាក់ក្នុងការធ្វើកំណែទម្រង់វិស័យអប់រំ ដើម្បីធ្វើឱ្យវិស័យអប់រំកម្ពុជា មានការរីកចម្រើន និងមានសក្តានុពលក្នុងតំបន់ និងនៅលើសកលលោក ។ការធ្វើកំណែទម្រង់នេះត្រូវជានាឱ្យបាននូវលទ្ធផលសិក្សារបស់សិស្សមានការល្អប្រសើរឡើង ក្រោយការបញ្ចប់ការសិក្សានៅមធ្យមសិក្សា ដើម្បីប្រែក្លាយសិស្សជាធនធានមនុស្សដែលមានគុណភាព ដើម្បីប្រណាំងប្រជែងនៅក្នុងតំបន់និង ការបង្កើតវិស័យសេដ្ឋកិច្ចថ្មីៗ ដូចជាអេឡិចត្រូនិច កសិកម្មឡូជីស្ទីកនៅក្នុងយុគឌីជីថល (ហង់ជួន ណារ៉ុន ២០២១)។ ទន្ទឹមនឹងនេះផងដែរដើម្បីសម្រេចបាននូវ លទ្ធផលសិក្សារបស់សិស្សប្រកបដោយគុណភាព ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយស្តីពីគ្រូបង្រៀន គោលនយោបាយស្តីពីធនធានមនុស្សនៅក្នុងវិស័យអប់រំ ក្របខណ្ឌវាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅជាដើមដែលជាតុចូលយ៉ាងសំខាន់ក្នុងការសម្រេចបាននូវលទ្ធផលសិក្សារបស់សិស្ស ស្របតាមក្របខណ្ឌកម្មវិធីសិក្សា។ តែទោះបីជាក្រសួង ឬស្ថាប័នពាក់ព័ន្ធដទៃទៀតយកចិត្តទុកដាក់កំណែទម្រង់ការអប់រំ នេះយ៉ាងណាក៏ដោយ នៅតែមានបញ្ហាតិចឬច្រើនចៀសមិនផុតឡើយ។ ក្នុងនោះផងដែរបើយើងក្រឡេកទៅមើលលទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ២៧ ធ្នូ ២០២១ មានបេក្ខជនបានជាប់ត្រឹមតែ ៦៥.៦៦% បើធៀបនឹងឆ្នាំ២០១៩មាន ៦៨.៦២%ដែលមានភាគរយជាប់តិចជាង ២.៩៦% ស្ថានភាព ថយចុះ (សន្និបាទបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ២០២២)។ ក្នុងឆ្នាំសិក្សានេះផងដែរ ដោយមានការរីករាលដាលនៃជម្ងឺ កូវីដ-១៩ សិស្សានុសិស្សត្រូវរៀនបរិបទថ្មី តាមប្រព័ន្ធអនឡាញ ដែលត្រូវការជួយគាំទ្រខ្លាំងពីសំណាក់ឪពុកម្តាយឬអាណាព្យាបាលរបស់សិស្ស ដូចជាសម្ភារឌីជីថលសម្រាប់សិក្សា មានដូចជាស្មាតហ្វូន ថេបប្លេត ទូរទស្សន៍ ប្រព័ន្ធទូរសព្ទឬវ៉ាយហ្វាយ ការទំនាក់ទំនងល្អជាមួយសាលារៀន ការដាស់តឿន និងត្រួតពិនិត្យសកម្មភាពរៀនរបស់សិស្សក្នុងពេលរៀននិងក្រោយពេលរៀន តាមដានលទ្ធផលសិក្សារបស់កូន និងសិស្សខ្លួនឯងត្រូវមានឥរិយាបទសិក្សាជាវិជ្ជមានក្នុងការសិក្សា។ ទម្លាប់សិក្សារបស់សិស្សអាចមានភាពវិជ្ជមានផ្តល់កម្រិតការយល់ដឹងខ្ពស់ ស្វ័យភាពសិក្សា ខណៈពេលដែល

អាកប្បកិរិយាអវិជ្ជមានរបស់ពួកគេអាចមានការធ្វើឱ្យមានសកម្មភាពមិនល្អ និងទទួលបានលទ្ធផលសិក្សាមិនល្អ ដែលប៉ះពាល់ក្របខណ្ឌកម្មវិធីសិក្សារបស់ក្រសួងអប់រំ។ ជាទូទៅការយល់ឃើញជាវិជ្ជមានរបស់សិស្សក្នុងការសិក្សាអាចជួយបង្កើតអាកប្បកិរិយាវិជ្ជមានចំពោះការសិក្សា ដែលនឹងនាំទៅរកការអនុវត្ត ការសិក្សាកាន់តែប្រសើរឡើង។ មូលហេតុទាំងនេះហើយទើបធ្វើឱ្យអ្នកស្រាវជ្រាវសិក្សាប្រធានបទខាងលើ ។

## ១.៣- គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃសិក្សានេះមានចំនួនពីរ ៖

១- រកឱ្យឃើញពីឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេនៅមធ្យមសិក្សាទុតិយភូមិ នៅខេត្តត្បូងឃ្មុំ។

២- ប្រៀបធៀបឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេនៅមធ្យមសិក្សាទុតិយភូមិ នៅខេត្តត្បូងឃ្មុំដោយផ្អែកតាមភេទ និងកម្រិតថ្នាក់សិក្សា។

## ១.៤- សំណួរស្រាវជ្រាវ

ជាការឆ្លើយតបទៅនឹងគោលបំណងស្រាវជ្រាវខាងលើ អ្នកស្រាវជ្រាវបានកំណត់នូវសំណួរស្រាវជ្រាវដូចខាងក្រោម៖

១- តើទម្លាប់សិក្សារបស់សិស្សមានផលប៉ះពាល់ដល់លទ្ធផលរៀនសូត្ររបស់ពួកបានកម្រិតណា?

២- តើមានភាពខុសគ្នាដែរឬទេ ចំពោះឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សលើលទ្ធផលរៀនសូត្ររបស់ពួកគេដោយផ្អែកលើភេទ និងកម្រិតថ្នាក់សិក្សា?

## ១.៥- សារៈសំខាន់នៃការស្រាវជ្រាវ

ការរកឃើញនៃការស្រាវជ្រាវនេះមានគោលបំណងសិក្សាពី ឥទ្ធិពលនៃទម្លាប់សិក្សាលើលទ្ធផលរៀនសូត្ររបស់សិស្សនៅមធ្យមសិក្សាទុតិយភូមិ ករណីសិក្សាខេត្តត្បូងឃ្មុំ។ វានឹងមានសារៈសំខាន់ចំពោះសិស្សានុសិស្ស គ្រូបង្រៀន មាតាបិតា អ្នកប្រឹក្សាសាលា អ្នកបង្កើតគោលនយោបាយ និងរដ្ឋាភិបាលក្នុងការជួយ និងលើកទឹកចិត្តសិស្សឱ្យដឹងពីសារៈសំខាន់នៃទម្លាប់សិក្សារបស់ពួកគេ។ សិស្សនឹងទទួលបាន

អត្ថប្រយោជន៍កាន់តែច្រើនពីការរកឃើញនៃការសិក្សានេះ ដោយសារពួកគេនឹងត្រូវបានផ្តល់ជំនួយជាចាំបាច់ និងរបៀបជួយបង្កើតទម្លាប់សិក្សាល្អ ដែលនឹងជួយកែលម្អលទ្ធផលសិក្សារបស់ពួកគេ។ សិស្សក៏នឹងទទួលបានការផ្តល់ព័ត៌មាន អំពីផលជះនៃទម្លាប់សិក្សាដែលប៉ះពាល់ដល់លទ្ធផលសិក្សារបស់ពួកគេ ហើយលទ្ធផលនៃការសិក្សានេះ នឹងធ្វើឱ្យពួកគេដឹងពីទម្លាប់សិក្សាទូទៅក្នុងចំណោមសិស្សដទៃទៀត។

ការសិក្សានេះនឹងណែនាំគ្រូបង្រៀន និងអ្នកប្រឹក្សាសាលា ដែលតែងតែមានបំណងប្រាថ្នាចង់ឃើញសិស្សរបស់ពួកគេជាសិស្សល្អ ដោយផ្តល់ឱ្យពួកគេនូវបច្ចេកទេសត្រឹមត្រូវក្នុងការអភិវឌ្ឍទម្លាប់សិក្សា។ វានឹងបង្ហាញគ្រូបង្រៀន ពីទម្លាប់សិក្សារបស់សិស្សដើម្បីឱ្យគ្រូបង្កើតវិធីសាស្ត្រដែលមានប្រសិទ្ធភាពជាងមុនក្នុងការបង្រៀនមុខវិជ្ជារបស់ពួកគាត់សម្រាប់ ធ្វើឱ្យមានការយល់ដឹងកាន់តែប្រសើរឡើងរបស់សិស្ស។

ម្យ៉ាងវិញទៀត មាតាបិតា នឹងមើលឃើញពីតួនាទីដែលត្រូវបំពេញឱ្យកូនៗពួកគេ ក្នុងការផ្តល់នូវការលើកទឹកចិត្ត និងរង្វាន់ដល់សិស្ស ដើម្បីលើកទឹកចិត្តដល់ការបង្កើត និងថែរក្សាទម្លាប់សិក្សាដ៏ល្អក្នុងចំណោមសិស្សនៅកម្រិតគ្រួសារ។ក្នុងនោះផងដែរការសិក្សានឹងជួយរដ្ឋាភិបាលក្នុងការផ្តល់នូវសម្ភារៈសិក្សា និងសម្ភារៈបរិក្ខារចាំបាច់នានា ដើម្បីជំរុញសិស្សានុសិស្សឱ្យពង្រឹងទម្លាប់សិក្សាល្អ។ ជាងនេះទៅទៀតការសិក្សានឹងធ្វើជាឯកសារណែនាំ និងជាធនធានដល់អ្នកបង្កើតគោលនយោបាយ និងអ្នកពាក់ព័ន្ធក្នុងការអភិវឌ្ឍន៍សម្ភារៈសិក្សា និងសៀវភៅសិក្សា ដោយគិតគូរពីតម្រូវការ និងសេចក្តីប្រាថ្នារបស់សិស្ស នៅពេលពួកគេសិក្សាដើម្បីប្រឡងជាប់ទាំងកម្រិតមធ្យមសិក្សា និងឧត្តមសិក្សា។

សរុបមកការសិក្សាស្រាវជ្រាវនេះ វានឹងផ្តល់ជាឯកសារបង្ហាញផ្លូវមួយ សម្រាប់អ្នកតាក់តែងគោលនយោបាយ និងអ្នកពាក់ព័ន្ធទាំងអស់ ពិសេស គណៈនាយក គ្រូបង្រៀន និងអាណាព្យាបាលដែលជាអ្នកជួបផ្ទាល់ជាមួយសិស្ស បានយល់ដឹងពីទម្លាប់សិស្សរបស់សិស្ស ងាយស្រួលក្នុងការរកដំណោះស្រាយក្នុងជួយសិស្សឱ្យទទួលបានលទ្ធផលសិក្សាល្អ ប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់ ។

## ១.៦- ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនឹងធ្វើការសិក្សាអំពី "ឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សលើលទ្ធផលរៀនសូត្ររបស់សិស្សនៅមធ្យមសិក្សាទុតិយភូមិ ករណីសិក្សានៅខេត្តត្បូងឃ្មុំ"។ ការសិក្សាស្រាវជ្រាវនេះផ្តោតលើឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្ស ដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេនៅមធ្យមសិក្សាទុតិយភូមិ និងប្រៀបធៀបឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្ស ដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេនៅមធ្យមសិក្សាទុតិយភូមិ នៅខេត្តត្បូងឃ្មុំដោយផ្អែកតាមភេទ និងកម្រិតថ្នាក់សិក្សា។ ទិន្នន័យដែលប្រមូលយកមកវិភាគ ត្រូវបានធ្វើឡើងដោយកំណត់យកវិទ្យាល័យចំនួន០៦ គ្រូកំពុងបង្រៀនចំនួន ៥៥នាក់ និងសិស្សានុសិស្សចំនួន ១៨០នាក់ ក្នុងខេត្តត្បូងឃ្មុំ។

## ១.៧- រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះត្រូវបានធ្វើការបែងចែកជា ៥ ជំពូកធំៗ ដូចខាងក្រោម៖

**១.ជំពូកទី១៖** សេចក្តីផ្តើម ជំពូកនេះបង្ហាញពីលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរសម្មតិកម្មនៃការស្រាវជ្រាវ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**២.ជំពូកទី២៖** ការរំលឹកទ្រឹស្តី ក្នុងជំពូកនេះសិក្សាទៅលើការបង្ហាញ និងការពារអំណះអំណាងរបស់វត្ថុបំណងនៃការសរសេរនិក្ខេបបទដោយលើកទ្រឹស្តីរបស់អ្នកប្រាជ្ញ លិខិតបទដ្ឋានគតិយុត្តិសំខាន់ៗ ឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងតួនាទីកិច្ចរបស់សហគមន៍ចំពោះលទ្ធផលសិក្សារបស់សិស្ស។

**៣.ជំពូកទី៣៖** វិធីសាស្ត្រនៃការស្រាវជ្រាវ ជំពូកនេះនិងលើកឡើងពីវិធីសាស្ត្រការស្រាវជ្រាវ និងគម្រោងនៃការវិភាគដោយកំណត់ទៅលើអថេរឯករាជ្យ និងអថេរមិនឯករាជ្យ សម្រាប់ការសិក្សាបង្ហាញពីការកំណត់ពេលវេលានិងទីកន្លែងគោលដៅដែលត្រូវសិក្សាស្រាវជ្រាវ។ នៅក្នុងជំពូកនេះអ្នកស្រាវជ្រាវបានបង្ហាញពីរបៀបស្រាវជ្រាវ នៃការសិក្សាប្រមូលភាគសំណាក ការប្រមូលព័ត៌មានការប្រើប្រាស់ឧបករណ៍ស្ថិតិ ការប្រើរូបមន្តសម្រាប់ការគណនា និងការជ្រើសរើសវិធីសាស្ត្រប្រមូលទិន្នន័យ។

**៤. ជំពូកទី៤៖** លទ្ធផល និងការបកស្រាយ ក្នុងផ្នែកនេះអ្នកស្រាវជ្រាវលើកឡើងពីលក្ខណៈជាក់ស្តែងដែលខ្លួនបានសិក្សារួចហើយ គឺត្រូវឆ្លើយតបទៅនិងចំណុច ដែលចោទសួរក្នុងចំណោចបញ្ហា។

ការបកស្រាវត្រូវបកស្រាវយ៉ាងលម្អិតទៅលើគោលដៅនៃការស្រាវជ្រាវដោយយោងលើលទ្ធផលនៃការស្រាវជ្រាវ ដោយយោងទៅលើលទ្ធផលនៃការស្រាវជ្រាវទ្រឹស្តីឬ ខ្លឹមសារ ដែលមានក្នុងកម្រងសំណួរ។

**៥.ជំពូកទី៥៖** សេចក្តីសន្និដ្ឋាននិងការផ្តល់សំណូមពរ ជំពូកនេះអ្នកស្រាវជ្រាវត្រូវធ្វើការសង្ខេបការសិក្សាស្រាវជ្រាវរួចទាញសេចក្តីសន្និដ្ឋាន លើគ្រប់ចំណុចដែលបានវិភាគ និងផ្តល់យោបល់និងសំណូមពរ ទៅលើចំណុចដែលត្រូវកែលម្អ ឬចំណុចខ្វះខាត។

# ជំពូកទី២

# ការរំលឹកទ្រឹស្តី

# ជំពូកទី ២

# ការរំលឹកទ្រឹស្តី

## ២.១- សេចក្តីផ្តើម

ជំពូកនេះបង្ហាញពីបញ្ញត្តិនិងទ្រឹស្តីដែលទាក់ទង នឹងគាំទ្រការស្រាវជ្រាវ។ចំណេះដឹងដែលទទួលបានយ៉ាងទូលំទូលាយបង្កើតបានជាប្រវត្តិសាស្ត្រមួយសម្រាប់ការវិភាគ និងការបកស្រាយជាបន្តបន្ទាប់នៃទិន្នន័យដែលប្រមូលបានសម្រាប់ការសិក្សាស្រាវជ្រាវបន្តបន្ទាប់ទៀត។ ការផ្តែកលើការពិនិត្យឡើងវិញនៃទ្រឹស្តីដែលពាក់ព័ន្ធនឹងជំពូកនេះ មានប្រធានបទជាច្រើនត្រូវបានពិពណ៌នាបកស្រាយ និងលើកបង្ហាញ។ ទិដ្ឋភាពនៃទម្លាប់សិក្សាត្រូវបានពិនិត្យឡើងវិញដោយគំរូទ្រឹស្តី និងលក្ខណៈនៃការអនុវត្តការសិក្សារបស់សិស្ស។ លើសពីនេះទៅទៀតការវាស់ស្ទង់ ការយល់ឃើញពីអត្ថប្រយោជន៍នៃទម្លាប់សិក្សា ពីការសិក្សាស្រាវជ្រាវមុនត្រូវបានពិភាក្សាជាចម្បង។

## ២.២- និយមន័យនៃពាក្យគន្លឹះ

យោងតាមប្រភពផ្សេងៗ និយមន័យនៃ**ទម្លាប់** ត្រូវបានអ្នកសិក្សាឱ្យនិយមន័យផ្សេងៗគ្នា។

Bernard (1990) បានកំណត់ទម្លាប់ថាជា ទង្វើ ឬគំរូនៃឥរិយាបទដែលមានលទ្ធផលយ៉ាងងាយស្រួល តាមរយៈការអនុវត្ត ដែលពួកវាកើតឡើងដោយឯកឯង ឬដោយស្វ័យប្រវត្តិក្នុងស្ថានភាពមួយដោយមិនមានការគិត ឬការផ្តោតអារម្មណ៍។ ទម្លាប់សំដៅលើការអនុវត្ត ឬអាកប្បកិរិយាធម្មតាដែលមិនអាចបោះបង់បានដោយងាយៗ។ ទម្លាប់សន្សំពេលវេលានិងបង្កើតសម្រាប់សេដ្ឋកិច្ចនៃសកម្មភាព ការលះបង់ពេលវេលា និងការគិត ដើម្បីទទួលបានចំណេះដឹង និងមានការប្រឡងយ៉ាងជិតស្និទ្ធលើមុខវិជ្ជាណាមួយជាពិសេសពីសៀវភៅ (Denga, 1998)។

Iheanacho (2002) អាកប្បកិរិយាដែលត្រូវបានពង្រឹងទំនងជាក្លាយជាទម្លាប់។ ការពង្រឹងបង្កើនប្រូបាប៊ីលីតេដែលការឆ្លើយតបដែលបានផ្តល់ឱ្យនឹងត្រូវបានធ្វើម្តងទៀតបង្កើតជាទម្លាប់។ ដោយមើលឃើញពីទំនាក់ទំនងខាងលើ ការបង្កើតទម្លាប់អាចត្រូវបានគេកំណត់ និងយល់បានល្អបំផុត នៅពេលដែល

គេពិចារណាថាអាកប្បកិរិយាដែលជំរុញទឹកចិត្តហើយរក្សាបានក្នុងរយៈពេលដ៏យូរ។ដូច្នេះហើយការបង្កើត និងរក្សាទម្លាប់សិក្សាឱ្យបានល្អទាមទារឱ្យមានការពង្រឹងសមត្ថភាព និងចំណេះដឹងច្បាស់លាស់អំពីអ្វីដែលត្រូវធ្វើនៅពេលសិស្សអាន។

ទាក់ទងនឹងការលើឡើងនេះ Hornby (1998) បានកត់សម្គាល់ថា ការសិក្សា គឺជាចំណែកពិសេសនៃការអានដែលទាមទារការលះបង់ពេលវេលា និងជាពិសេសការយកចិត្តទុកដាក់ក្នុងការទទួលបានចំណេះដឹងពីសៀវភៅ។ លក្ខណៈរបស់សិស្សចំពោះការបរាជ័យក៏ជាឥទ្ធិពលសំខាន់លើការបង្កើតទម្លាប់ផងដែរ។ នៅពេលដែលសិស្សមានប្រវត្តិបរាជ័យក្នុងសាលារៀន វាតែជួយលើកទឹកចិត្តពួកគេឱ្យរក្សាការលើកទឹកចិត្តដើម្បីបន្តការព្យាយាមបន្តទៀត។ សិស្សដែលជឿថាលទ្ធផលសិក្សាមិនល្អរបស់ពួកគេគឺបណ្តាលមកពីកត្តាដែលមិនមានការគ្រប់គ្រងពេលវេលារបស់ពួកគេ ទំនងជាឃើញហេតុផលណាមួយដែលសង្ឃឹមថានឹងមានភាពប្រសើរឡើងក្នុងការបង្កើតទម្លាប់សិក្សានេះ។ គ្រូបង្រៀនអាចដឹងពីអាកប្បកិរិយារបស់សិស្សដែលថា តើត្រូវពង្រឹងសមត្ថភាពឬកែប្រែ ដើម្បីរំពឹងទុកលទ្ធផលសិក្សារបស់សិស្សម្នាក់ៗតាមរយៈការបង្រៀន (Graham, 1990)។ នេះនឹងអនុញ្ញាតឱ្យសិស្សបង្កើតអាកប្បកិរិយាល្អចំពោះការបង្កើតទម្លាប់សិក្សា ដែលជះឥទ្ធិពលដល់ដំណើរការសិក្សារបស់ពួកគេ។

### ២.២.១- លក្ខណៈនៃទម្លាប់

- ទម្លាប់មិនមែនកើតមានពីកំណើតទេ។
- ទម្លាប់នាំមកនូវភាពត្រឹមត្រូវក្នុងសកម្មភាព។
- សកម្មភាពបង្កើតជាទម្លាប់ដែលបានអនុវត្តដោយភាពងាយស្រួល ។
- ទម្លាប់ត្រូវបានគេអនុវត្តរាល់ពេលតាមរបៀបដដែលៗ។
- ទម្លាប់ត្រូវបានអនុវត្តដោយយកចិត្តទុកដាក់តិចបំផុត ឬគ្មានការយកចិត្តទុកដាក់។
- ប្រព័ន្ធប្រសាទគឺជាកត្តាគោលការណ៍ក្នុងការបង្កើតទម្លាប់។

### ២.២.២- សារៈសំខាន់នៃទម្លាប់

តាមរយៈការបង្កើតទម្លាប់ វាមិនអាចកើតមានឡើងទេបើយើងធ្វើរឿងជាច្រើនក្នុងពេលតែមួយ។ ដូច្នេះវាចាំបាច់ណាស់ដែលត្រូវមានការកំណត់ត្រឹមត្រូវក្នុងការយកទៅបង្កើតទម្លាប់លើ ការងារ ការគិត និងលើផ្លូវអារម្មណ៍របស់កុមារតាំងពីការចាប់ផ្តើមក្នុងការសិក្សាដំបូងមក។ ទម្លាប់មានឥទ្ធិពលខ្លាំងនៅក្នុងវិស័យអប់រំផងដែរ។ សិស្សដែលមានទម្លាប់ផ្តោតលើការសិក្សាជាច្រើនម៉ោងក្នុងសាលាក៏ដូចនៅផ្ទះពួកគេមិនងាយចុះចាញ់ដោយការនឿយហត់នោះទេ។ ទម្លាប់នៃការគិតទៀងទាត់ ការវែកញែកបានត្រឹមត្រូវ និងទាន់ពេលវេលាជួយសិស្សក្នុងការកែតម្រូវ ក្នុងការរៀនសូត្រ និងសម្រេចបាននូវចំណេះដឹង និងជំនាញសំខាន់ៗទាំងអស់ក្នុងរយៈពេលដ៏ខ្លី ជាមួយនឹងភាពងាយស្រួលដ៏អស្ចារ្យ។ ទម្លាប់នៃការអានទស្សនាវដ្តី កាសែត ស្តាប់វិទ្យុ ធ្វើការវិភាគ និងការអានសៀវភៅបុរាណ រឿងច្នៃប្រឌិតរបស់អ្នកនិពន្ធត្រូវតែបណ្តុះលើសិស្សនៅសាលា ហើយអនុវត្តនៅក្នុងមហាវិទ្យាល័យ និងនៅពេលក្រោយក្នុងជីវិត។

## ២.៣- និយមន័យទម្លាប់សិក្សា

ទម្លាប់នៃការសិក្សា ជំរុញ និងណែនាំដំណើរការយល់ដឹងរបស់បុគ្គលម្នាក់អំឡុងពេលសិក្សា ហើយវាដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការសិក្សារបស់សិស្ស។ ដោយមើលឃើញពីបញ្ហានេះ អ្នកស្រាវជ្រាវមួយចំនួន (Reyes, J. C. 2011) បានបង្ហាញថា លទ្ធផលសិក្សារបស់សិស្សគឺជាផលិតផលនៃកត្តាអន្តរកម្ម ដូចជា ទម្លាប់សិក្សាល្អ និងមានប្រសិទ្ធភាព ជំនាញរបស់គ្រូ បរិយាកាសសាលា និងអាណាព្យាបាល។ ទោះជាយ៉ាងណាក៏ដោយ ក្របខ័ណ្ឌគំនិតដែលមានស្តីពីទម្លាប់សិក្សា បង្ហាញថាការសិក្សាជោគជ័យ និងការយល់ដឹងពីអ្វីដែលត្រូវបានបង្រៀននៅក្នុងសាលា គឺជាកត្តាសំខាន់បំផុតក្នុងការទទួលបានលទ្ធផលល្អក្នុងការសិក្សា និងការចូលរួមយ៉ាងពេញលេញនៅក្នុងសង្គម។

Asaqwara (1994) យល់ឃើញថា ទម្លាប់សិក្សាល្អមានន័យថា ជាការជម្នះលើភាពទាក់ទាញផ្សេងៗដែលកើតឡើងជាមួយបរិយាកាសសិក្សាទាំងខាងក្នុង និងខាងក្រៅ ដូចជាការមើលភាពយន្តពេលកំពុងសិក្សា សំលេងរំខាន ការអានសៀវភៅផ្សេងៗ ការពិភាក្សា និងស្ថានភាពចិត្តរបស់អ្នកសិក្សា។

Mazuar ( 2000 ), Asaqwara ( 1994 ) និង Iheanacho ( 2002 ) បានបញ្ជាក់បន្ថែមអំពីឥទ្ធិពលនៃទម្លាប់សិក្សាមិនល្អ ហើយបានបង្ហាញថាទម្លាប់សិក្សាមិនល្អធ្វើឱ្យការសិក្សាមានភាពយ៉ាប់យ៉ឺន និងពិបាក។ ក្នុងចំណោមគុណវិបត្តិផ្សេងទៀតនៅក្នុងប្រព័ន្ធអប់រំ ទម្លាប់សិក្សារបស់សិស្សដើរតួនាទីយ៉ាងសំខាន់ក្នុងការឆ្លុះបញ្ចាំងពីស្តង់ដារនៃការអប់រំ និងការអនុវត្តបុគ្គលរបស់សិស្ស។

Sorenson ( 1991 ) បានរៀបរាប់ពីទម្លាប់សិក្សាជាមូលដ្ឋានដ៏ល្អ បាននិយាយថា មនុស្សម្នាក់ត្រូវតែសិក្សាដោយចេតនាជាចម្បងនៃការយល់ដឹង។ នេះតម្រូវឱ្យអ្នកមិនប្រញាប់ប្រញាល់គិតអ្វីមួយលឿនពេកឡើយ ផ្ទុយទៅវិញការផ្តោត អារម្មណ៍ជានិរន្តរភាពគឺជាការចាំបាច់។

Crow ( 1992 ) បានយល់ឃើញថា ទម្លាប់នៃការសិក្សាប្រកបដោយប្រសិទ្ធភាពរួមមាន ផែនការទីកន្លែង តារាងពេលវេលាច្បាស់លាស់ និងការកត់ត្រាសង្ខេបនៃការរៀបចំយ៉ាងល្អ។

យោងតាម Patel ( 1981 ) ទម្លាប់សិក្សារួមមាន

- បរិយាកាសក្នុងផ្ទះ
- ទម្លាប់អាន និងធ្វើកំណត់ត្រា
- ការធ្វើផែនការមុខវិជ្ជា
- ទម្លាប់នៃការផ្តោតអារម្មណ៍
- ការរៀបចំសម្រាប់ការប្រឡង
- បរិយាកាសសាលា។

ទម្លាប់សិក្សាដែលមានប្រសិទ្ធភាពនាំឱ្យមានលទ្ធផលសិក្សាជាវិជ្ជមាន ខណៈដែលទម្លាប់សិក្សាដែលមានបញ្ហានាំឱ្យមានលទ្ធផលសិក្សាមិនល្អ (Akinboye, 1980)។ ការលើកឡើងស្រដៀងគ្នា Kemjika (1998) បាននិយាយថាសម្រាប់ទម្លាប់សិក្សាដើម្បីចាត់ទុកថាមានប្រសិទ្ធភាព មានសមាសធាតុជាមូលដ្ឋានដូចជា ការធ្វើផែនការ និងគោរពតាមកាលវិភាគសិក្សាប្រចាំថ្ងៃ ការចូលរួមយ៉ាងពេញលេញក្នុងដំណើរការបង្រៀន និងរៀនបណ្តុះទម្លាប់នៃការអានឱ្យបានល្អ និងបំពេញការងារក្នុងថ្នាក់ និងកិច្ចការឱ្យទាន់ពេលវេលា ការកត់ត្រាចំណុចសំខាន់ៗនៅពេលគ្រូកំពុងបង្រៀន និងអំឡុងពេលស្វ័យ

សិក្សា។ទម្លាប់សិក្សាល្អគឺជាធាតុផ្សំដ៏សំខាន់សម្រាប់ដំណើរការសិក្សាដ៏ល្អឥតខ្ចោះសម្រាប់សិស្សគ្រប់រូប។ ការសង្កេតនេះគឺស្របទៅនឹង Onyejiaku (1987) ដែលបានស្នើថា បច្ចេកទេសសិក្សាដែលគ្មានប្រសិទ្ធភាព គឺជាកត្តាចម្បងដែលជាហេតុធ្វើឱ្យប៉ះពាល់ ចំពោះចំណាត់ថ្នាក់មិនល្អ ឬការបរាជ័យក្នុងការសិក្សា។ ម្យ៉ាងវិញទៀត Azikiwe (1998) ចាត់ទុកទម្លាប់សិក្សាថាជា "វិធី និងរបៀបដែលសិស្សរៀបចំផែនការអានជាលក្ខណៈឯកជនបន្ទាប់ពីរៀនក្នុងថ្នាក់រៀនដើម្បីគ្រប់គ្រងមុខវិជ្ជា។

យោងទៅតាម Azikiwe ទម្លាប់សិក្សាល្អគឺជា "ទ្រព្យសម្បត្តិដ៏ល្អសម្រាប់អ្នកសិក្សា ព្រោះទម្លាបជួយសិស្សឱ្យសម្រេចបាននូវជំនាញឯកទេស និងលទ្ធផលនៃការអនុវត្តដ៏ល្អឥតខ្ចោះ ខណៈដែលផ្ទុយពីនេះវាបង្កើតជាឧបសគ្គដល់ការរៀនសូត្រ និងការអនុវត្តដែលនាំឱ្យបរាជ័យ។ គោលបំណងសំខាន់នៃការណែនាំគឺដើម្បីឱ្យសិស្សរៀនបាន ចំណែកភារកិច្ចរបស់គ្រូគឺជួយសម្រួលដល់ដំណើរការសិក្សា និងជួយសិស្សបង្កើតទម្លាប់សិក្សា និងអាកប្បកិរិយាត្រឹមត្រូវចំពោះការសិក្សា។

ចំណុចមួយទៀតដែលបានបង្ហាញដោយសមហេតុផលដោយ Bojuwoye (1993) ដែលបានអះអាងថា ផ្នែកសំខាន់មួយដែលសិស្សត្រូវការ ការរៀបចំដើម្បីបង្កើនសមត្ថភាពរបស់ពួកគេគឺការរៀនពីរបៀបសិក្សា ហើយការខ្វះខាតទម្លាប់សិក្សាដែលមានប្រសិទ្ធភាពគឺជាបញ្ហាអប់រំទូទៅក្នុងចំណោមសិស្សវិទ្យាល័យ។ .

Jacobson (1980) បានអះអាងថា សិស្សដែលបានបែងចែកពេលវេលាបានល្អដើម្បីសិក្សាបង្ហាញពីការទទួលបានលទ្ធផលកាន់តែខ្ពស់។ ទោះបីជា Svensson (1997) បានយល់ស្របថាទំនាក់ទំនងរវាងទម្លាប់សិក្សា និងការលទ្ធផលសិក្សារបស់សិស្សគឺសំខាន់បំផុតក៏ដោយ។ Svensson បានរិះគន់កិច្ចខិតខំប្រឹងប្រែងស្រាវជ្រាវមុននេះដោយផ្អែកលើការពិតដែលថាអថេរដែលបានប្រើត្រូវបានដាក់ទ្រឹស្តីទៅលើបាតុភូតនេះ។

ដើម្បីឱ្យការសិក្សាមានប្រសិទ្ធភាព Freeman and Morss (1993) បានសង្កេតឃើញថា វាគួរតែទៀងទាត់ខ្លាំង និងគួរគ្របដណ្តប់រយៈពេលយូរ។ ទម្លាប់នៃការសិក្សាត្រូវតែមាននិរន្តរភាពសម្រាប់បញ្ហានោះគឺ សិស្សត្រូវមើលឃើញពីតម្រូវការក្នុងការអភិវឌ្ឍទម្លាប់សិក្សាល្អ។ វាត្រូវបានគេជឿថាទម្លាប់សិក្សាល្អ និងអាកប្បកិរិយាវិជ្ជមានចំពោះការសិក្សាដែលបង្ហាញ ឱ្យឃើញនៅក្នុងការសិក្សាជាច្រើនលើកកម្ពស់

ដំណើរការនៃការសិក្សាជំនាញពិសេស រួមទាំងជំនាញវែកញែកផងដែរ។ ទម្លាប់នៃការសិក្សាល្អនាំទៅដល់ការពង្រឹងការរៀនសូត្រ ព្រោះថា "សមត្ថភាពប្រសើរឡើង និងធ្វើឱ្យកាន់តែច្បាស់តាមរយៈភាពប៉ិនប្រសប់នៃគោលការណ៍ និងដោយមធ្យោបាយនៃការបណ្តុះបណ្តាល ការធ្វើលំហាត់ប្រាណ និងការអនុវត្តជាប្រចាំ ( Ortinero , 2000)។ ការសិក្សារបស់ Weiner (1972) បង្ហាញពីសមត្ថភាពនោះ ក៏ដូចជាការខិតខំប្រឹងប្រែងដែលបានផ្តល់ឱ្យដោយសិស្សក្នុងការសិក្សារបស់ពួកគេ ប៉ះពាល់ដល់ការទទួលបានជំនាញគិត និងការអនុវត្តការសិក្សា។

ទម្លាប់សិក្សាមានសារៈសំខាន់ ព្រោះវាមានឥទ្ធិពលលើការអនុវត្តការសិក្សារបស់សិស្ស ដូច្នេះឪពុកម្តាយ និងគ្រូបង្រៀនត្រូវតែជួយក្នុងការកែលម្អទម្លាប់សិក្សារបស់សិស្ស។ អ្នកស្រាវជ្រាវមួយចំនួនបានធ្វើការស្ទង់មតិដើម្បីកំណត់នូវទម្លាប់សិក្សាដែលសិស្សប្រើប្រាស់ជាលក្ខណៈរួម នៅពេលដែលពួកគេចាកចេញទៅធ្វើការដោយខ្លួនឯងដោយមានទិសដៅតិចតួច ឬគ្មាន ដូច្នេះ គ្រូបង្រៀននៅក្នុងសាលារៀនគួរតែជាអ្នកសម្របសម្រួលនៅពេលសិស្សរៀនសូត្រ។ កំណប់ទ្រព្យដ៏មានតម្លៃកំណត់នៅក្នុងអ្នកសិក្សាគ្រប់រូបគួរត្រូវបានរកឃើញ និងថែរក្សាក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវជំនាញសិក្សាប្រកបដោយប្រសិទ្ធភាព។ ការរៀនមានភាពប្រសើរឡើងជាមួយនឹងការរៀបចំផែនការទីកន្លែង ពេលវេលា និងរយៈប៉ុន្មានដែលត្រូវសិក្សា។

## ២.៤- ទម្លាប់សិក្សារបស់សិស្ស និងសារៈសំខាន់របស់ទម្លាប់

វិធីសាស្ត្រក្នុងការរៀនរបស់សិស្សគឺមានលក្ខណៈបុគ្គលខ្ពស់ជាមួយនឹងការប្រែប្រួលយ៉ាងទូលំទូលាយនៃបច្ចេកទេស។ សិស្សម្នាក់អាចចូលចិត្តបណ្ណាល័យស្ងប់ស្ងាត់ ម្នាក់អាចគូសបន្ទាត់ពីក្រោមអត្ថបទ ម្នាក់ទៀតកត់ចំណាំ ម្នាក់អាចសិក្សាយ៉ាងយកចិត្តទុកដាក់រយៈពេលជាច្រើនម៉ោង សិស្សម្នាក់ទៀតអាចសម្រាកជាច្រើនថ្ងៃ Onyejiaku (1987)។ ការប្រែប្រួលគឺគ្មានទីបញ្ចប់ ហើយការអប់រំចាត់ទុក ថាជាដំណើរការសិក្សាអាចមានផលិតភាពកាន់តែច្រើន ប្រសិនបើអ្នកសិក្សាត្រូវបានបង្រៀនជំនាញ និងបច្ចេកទេសជាក់លាក់ដែលនឹងធ្វើឱ្យដំណើរការសិក្សាជាផ្លូវការ ហើយដោយហេតុនេះធ្វើឱ្យវាកាន់តែមានប្រសិទ្ធភាព។ នៅក្នុងដំណើរការនៃការសិក្សាទម្លាប់នៃការអនុវត្ត និងការអនុវត្តសមត្ថភាពនៃការរៀនសូត្រ

របស់ពួកគេត្រូវបានចាត់ទុកថាជាទម្លាប់សិក្សារបស់អ្នកសិក្សា។ គំរូនៃអាកប្បកិរិយាដែលបានអនុម័តដោយសិស្សក្នុងការបន្តការសិក្សារបស់ពួកគេត្រូវបានពិចារណានៅក្រោមចំណងជើងនៃទម្លាប់សិក្សារបស់ពួកគេ (Jacobson, 1980) ។

ការទទួលបានចំណេះដឹងប្រកបដោយប្រសិទ្ធភាពគឺអាស្រ័យលើវិធីសាស្ត្រនៃការទទួលបានទម្លាប់សិក្សាល្អ។ វាមានសារៈសំខាន់ និងគួរឱ្យចង់បានដែលការស៊ើបអង្កេតលើគំរូនៃទម្លាប់សិក្សារបស់សិស្សត្រូវបានធ្វើឡើង។ Kholi (1997) បានស្រាវជ្រាវលើភាពខុសគ្នារវាងសិស្សឥណ្ឌា និងអឺរ៉ុប-អាមេរិកនៅក្នុងទម្លាប់សិក្សារបស់ពួកគេ ហើយបានបង្ហាញថា សិស្សឥណ្ឌាត្រូវគាំពារ ប៉ុន្តែនិស្សិតអឺរ៉ុប-អាមេរិកចូលចិត្តការសិក្សាឯករាជ្យក្រោមការគ្រប់គ្រងរបស់គ្រូ ឬអ្នកគ្រប់គ្រងរបស់គាត់។ .

### ២.៤.១- ការអភិវឌ្ឍន៍ទម្លាប់សិក្សាល្អ

សិស្សានុសិស្សក្នុងវ័យកុមារភាពរបស់ពួកគេមានការចាប់អារម្មណ៍ និងលត់ដំខ្លួនកាន់តែច្រើនលើអ្វីៗគ្រប់យ៉ាង ហើយប្រសិនបើឪពុកម្តាយ និងគ្រូបង្រៀនបណ្តុះទម្លាប់ល្អ នោះវានឹងមានប្រយោជន៍ក្នុងការសិក្សារបស់ពួកគេនាពេលអនាគត។ យោងតាម Kemjika (1998) ទាំងនេះគឺជាចំណុចមួយចំនួនដែលត្រូវប្រើក្នុងការអភិវឌ្ឍទម្លាប់សិក្សាល្អក្នុងចំណោមសិស្ស៖

- រៀបចំផែនការសកម្មភាព និងពេលវេលាឱ្យបានត្រឹមត្រូវសម្រាប់មួយថ្ងៃ និងមួយសប្តាហ៍ផងដែរ។
- ផ្តល់ពេលវេលាបន្ថែមទៀតសម្រាប់ការសិក្សាមុខវិជ្ជាពិបាកៗតាមកាលវិភាគ ហើយធ្វើតាមដោយទៀងទាត់។
- បរិយាកាសអំណោយផលផ្តល់នូវការផ្តោតអារម្មណ៍ល្អ។
- ពេលកំពុងសិក្សា សូមកាន់សៀវភៅនៅមុំមួយ និងចំងាយប្រហែល 25cm។
- បំបែកខ្លឹមសារទាំងមូលទៅជាកថាខណ្ឌតូចៗ អនុវត្តការសង្ខេបកថាខណ្ឌនីមួយៗឱ្យបានរហ័សក្នុងចិត្ត។
- បង្កើតអាកប្បកិរិយានៃការសួរខ្លួនឯង និងអ្នកដទៃអំពីចំណុចដែលអ្នកបានអាន។

- រៀបចំកំណត់ចំណាំខ្លីៗអំពីអ្វីដែលអ្នកអាន ក្រៅពីការកត់ចំណាំឈ្មោះសៀវភៅ និងលេខទំព័រនៅក្នុងនោះ ប្រសិនបើប្រើសៀវភៅផ្សេងទៀត។
- សម្រាប់ការត្រួតពិនិត្យឡើងវិញ វាជាការប្រសើរជាងដែលអ្នកគូសបញ្ជាក់ចំណុចសំខាន់ៗ ប្រធានបទ និងសំណួរ។

➢ ទន្ទេញរូបមន្ត គោលការណ៍ និមិត្តសញ្ញា និងច្បាប់ដែលត្រូវការម្តងហើយម្តងទៀត។

## ២.៥- កត្តាដែលជះឥទ្ធិពលដល់ទម្លាប់សិក្សារបស់សិស្សវិទ្យាល័យ

Etsey (2004) ណែនាំថាកត្តាសំខាន់ៗដែលមានឥទ្ធិពលលើទម្លាប់សិក្សារបស់សិស្សគឺ៖

- ផ្ទះ គឺជាសាលាដំបូងសម្រាប់កូនគ្រប់រូប ហើយម្តាយគឺជាគ្រូដំបូង។ ប្រសិនបើបរិយាកាសក្នុងផ្ទះល្អ ធម្មជាតិរបស់កុមារនៅក្នុងសាលារៀននឹងល្អដោយស្វ័យប្រវត្តិផងដែរ។ អាស្រ័យហេតុនេះ ទំនាក់ទំនងជាមួយសមាជិកគ្រួសារដូចជា ឪពុកម្តាយ បងប្អូនប្រុសស្រី មានឥទ្ធិពលលើការសិក្សារបស់កុមារ។

- បន្ទាប់ពីផ្ទះ កុមារចំណាយពេលច្រើនក្នុងសាលារៀន ហើយសម្រាប់បញ្ហានោះ បរិយាកាសសាលាគួរតែល្អ។ គ្រូបង្រៀន និងក្រុមមិត្តភ័ក្តិក៏ដើរតួយ៉ាងសំខាន់ក្នុងទម្លាប់សិក្សារបស់កុមារផងដែរ។ មាតាបិតាគួរតាមដានមិត្តភ័ក្តិរបស់កូន ព្រោះបើមានមិត្តល្អ កូនរៀនទម្លាប់ល្អ។

- កម្មវិធីសិក្សា ក៏ជាកត្តាមួយសម្រាប់បង្កើតទម្លាប់សិក្សាល្អផងដែរ។ កម្មវិធីសិក្សាគួរតែត្រូវបានបង្កើតឡើងតាមស្តង់ដាររបស់កុមារ។

- ក្រៅពីចំណុចខាងលើ បុគ្គលិកលក្ខណៈរបស់សិស្សជាកត្តាសំខាន់ណាស់ក្នុងការបង្កើតទម្លាប់សិក្សាឲ្យបានល្អ។ ប្រសិនបើសិស្សសម្របតាមបរិយាកាសបានយ៉ាងងាយ សិស្សនោះនឹងបង្កើតទម្លាប់សិក្សាបានល្អ។

- បើកត្តាបុគ្គលិកលក្ខណៈល្អ កត្តាបញ្ញាក៏ល្អដែរ។ ភាពវៃឆ្លាតក៏ដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍទម្លាប់សិក្សាដ៏ល្អរបស់សិស្សផងដែរ។ វាជាការសង្កេតទូទៅដែលសិស្សឆ្លាតវៃឈរក្នុងតំណែងកំពូល។

លទ្ធផលការសិស្សនេះភាគច្រើនសិស្សមានអាយុពី១៥-១៨ឆ្នាំ។កុមារនៅប្រទេសកម្ពុជាចាប់ផ្តើមការអប់រំរបស់ពួកគេចូល សាលាបឋមសិក្សានៅអាយុ៦ឆ្នាំ រួចត្រូវសិក្សាបន្តនៅអនុវិទ្យាល័យ វិទ្យាល័យ និងទីបំផុតសាកលវិទ្យាល័យ។ អាយុគឺជាសន្ទស្សន៍នៃភាពចាស់ទុំ និងភាពចាស់ទុំដែលជួយដល់ការរៀនសូត្រ។ ការពន្យល់នេះត្រូវបានគាំទ្រដោយការងាររបស់អ្នកស្រាវជ្រាវពីមុន (Waldman, 1986; Sturman, 2003; and Kumar, 2002) ដែលបានរកឃើញទំនាក់ទំនងវិជ្ជមានកម្រិតមធ្យមរវាងអាយុ និងការសិក្សា។ កត្តាអាយុត្រូវបានបង្ហាញថាមានសារៈសំខាន់ក្នុងការពន្យល់ពីលទ្ធផលសិក្សារបស់សិស្ស ហើយអាយុលេចឡើងជាអថេរពន្យល់ក្នុងការអភិវឌ្ឍទម្លាប់សិក្សាក្នុងចំណោមសិស្ស។ នៅពេលដែលសិស្សកាន់តែចាស់ ពួកគេធ្វើបានល្អក្នុងការសិក្សារបស់ពួកគេ។

តារាងទី៤៖ ភេទសិស្ស

| ភេទ | ចំនួន | ភាគរយ |
|---|---|---|
| ប្រុស | ៨៧ | ៤៨.៣ |
| ស្រី | ៩៣ | ៥១.៧ |
| សរុប | ១៨០ | ១០០ |

តារាងទី៤ បានបង្ហាញថាការឆ្លើយតបរបស់សិស្សនៅមធ្យមសិស្សសិក្សានៅខេត្តត្បូងឃ្មុំ ដែលមានវិទ្យាចំនួន៦ ចំនួន១៨០នាក់ ទៅលើភេទ មានសិស្សស្រីចំនួន ៩៣នាក់ ស្មើនឹង៥១.៧% ក្នុងនោះផងដែរមានសិស្សប្រុសចំនួន ១៩នាក់ ស្មើនឹង៤៨.៣%។

ការសិក្សានេះបង្ហាញថា មានភាពប្រហាក់ប្រហែលគ្នារវាងចំនួនសិស្សប្រុស និងចំនួនសិស្សដែលសិក្សានៅកម្រិតទុតិយភូមិ។ វាជាលទ្ធផលល្អមួយក្នុងការលើកកម្ពស់ យេនឌ័រ និងមានភាពងាយស្រួលក្នុងការទទួលបានសេវាអប់រំរបស់សិស្ស។ ឥទ្ធិពលនៃយេឌ័រដែលរំពឹងទុកនៅក្នុងសង្គមណាមួយគឺមាន

អារម្មណ៍តាំងពីកំណើត (Pringle, 1974) ។ គាត់បានលើកឡើងបន្ថែមទៀតថា សំលៀកបំពាក់ ប្រដាប់ប្រដាក្មេងលេង និងគំរូមាតាបិតារបស់កុមារជាមួយនឹងពិភពលោកដែលបែងចែកអាកប្បកិរិយាយ៉ាងច្បាស់ដែលរំពឹងទុកពីក្មេងប្រុស និងក្មេងស្រី។ នៅក្នុងសង្គមធំ បញ្ហាផ្សេងៗនៃសមត្ថភាពត្រូវបានគេមើលឃើញថាជាយេនឌ័រសមស្របនៅក្នុងវប្បធម៌ណាមួយ ហើយបញ្ហាទាំងនេះទាក់ទងនឹងការរំពឹងទុក និងគំរូដែលវប្បធម៌ប្រកាន់យកអំពីតួនាទីយេនឌ័រ។ កុមាររៀនប្រព្រឹត្តតាមរបៀបដែលសង្គមរបស់ពួកគេរំពឹងថានឹងមានយេនឌ័ររបស់ពួកគេប្រព្រឹត្ត។ សូម្បីតែការរៀបចំផ្ទះក៏ផ្តល់ការគាំទ្រច្រើនដល់ភាពខុសគ្នានៃតួនាទីយេនឌ័រដែរ។ ដូចដែលបានកត់សម្គាល់ខាងលើ ឪពុកម្តាយមានអាកប្បកិរិយាខុសពីកុមារដែលមានភេទផ្សេងគ្នា។

តារាងទី៥៖ កម្រិតអប់រំរបស់ឪពុកម្តាយ

| | កម្រិតនៃការអប់រំរបស់ឪពុក | | កម្រិតនៃការអប់រំរបស់ម្តាយ | |
|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មិនចេះអក្សរ | ១០ | ៥.៦ | ២២ | ១២.២ |
| បឋមសិក្សា | ១០២ | ៥៦.៧ | ៩៥ | ៥២.៨ |
| មធ្យមសិក្សាបឋមភូមិ | ៣៩ | ២១.៧ | ៤១ | ២២.៨ |
| មធ្យមសិក្សាទុតិយភូមិ | ១៨ | ១០ | ១៦ | ៨.៩ |
| បរិញ្ញាបត្ររង | ១ | 0.៦ | 0 | 0 |
| បរិញ្ញាបត្រ | ៦ | ៣.៣ | ៥ | ២.៨ |
| បរិញ្ញាបត្រជាន់ខ្ពស់ | ៤ | ២.២ | ១ | 0.៦ |
| សរុប | ១៨០ | ១០០ | 180 | 100 |

តារាងទី៥ បានបង្ហាញថាការឆ្លើយតបរបស់សិស្សនៅមធ្យមសិស្សសិក្សានៅខេត្តត្បូងឃ្មុំ ដែលមានវិទ្យាចំនួន៦ ចំនួន១៨០នាក់ ទៅលើកម្រិតអប់រំរបស់ឪពុកម្តាយ បានបង្ហាញថាសិស្សមានឪពុកមិនចេះអក្សរមានចំនួន ១០នាក់ស្មើនឹង៥.៦% និងសិស្សមានម្តាយមិនចេះអក្សរមានចំនួន ២២នាក់ស្មើនឹង ១២.២% ហើយសិស្សមានឪពុកសិក្សាត្រឹមកម្រិតបឋមសិក្សាចំនួន ១០២នាក់ស្មើនឹង៥៦.៧% និងសិស្សមានម្តាយសិក្សាត្រឹមកម្រិតបឋមសិក្សាមានចំនួន ៩៥នាក់ស្មើនឹង៥២.៨% រីឯសិស្សមានឪពុក

សិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ៤នាក់ស្មើនឹង២.២% និងសិស្សមានម្តាយសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ១នាក់ស្មើនឹង០.៦%។

ការសិក្សានេះបានបង្ហាញថា ឪពុកម្តាយសិស្សភាគច្រើនទទួលបានការអប់រំនៅកម្រិតបឋមសិក្សា និងភាគច្រើនឪពុកមានការសិក្សារៀនសូត្របានខ្ពស់ជាងម្តាយ។ Alexander (1994 )បានផ្តល់យោបល់ថា សមត្ថភាពរបស់មាតាបិតាក្នុងការបង្កើតជំនឿ និងការរំពឹងទុកដ៏ត្រឹមត្រូវទាក់ទងនឹងការបំពេញការងាររបស់កូនៗពួកគេមានសារៈសំខាន់ណាស់ក្នុងការរៀបចំរចនាសម្ព័ន្ធក្នុងផ្ទះ និងបរិយាកាសអប់រំ ដើម្បីឱ្យពួកគេអាចពូកែក្នុងការខិតខំប្រឹងប្រែងក្រោយចូលរៀន។ មានការស្រាវជ្រាវមួយចំនួនបានបង្ហាញថាការអប់រំខ្ពស់របស់ឪពុកម្តាយបានផ្សារភ្ជាប់គ្នាយ៉ាងសំខាន់ទៅនឹងអនាគតកូនៗរបស់ពួកគេ (Sewell and Shah, 1968)។

តារាងទី៦៖ មុខរបរឪពុកម្តាយ

| | **មុខរបរឪពុក** | | **មុខរបរម្តាយ** | |
|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មន្ត្រីរាជការ | ១៩ | ១០.6 | ៨ | ៤.៤ |
| ឯកជន | ៧ | ៣.៩ | ៧ | ៣.៩ |
| NGO (អង្គការក្រៅរដ្ឋាភិបាល) | ១ | ០.៦ | ១ | ០.៦ |
| កសិករ | ១៣៧ | ៧៦.១ | ១៤៥ | ៨០.៦ |
| ផ្សេងៗ | ១៦ | ៨.៩ | ១៩ | ១០.៦ |
| សរុប | ១៨០ | ១០០ | ១៨០ | ១០០ |

តារាងទី៦ បានបង្ហាញថាការឆ្លើយតបរបស់សិស្សនៅមធ្យមសិស្សសិក្សានៅខេត្តត្បូងឃ្មុំ ដែលមានវិទ្យាល័យចំនួន០៦ ចំនួន១៨០នាក់ ទៅលើមុខរបរឪពុកម្តាយសិស្ស បានបង្ហាញថាមានសិស្សមានឪពុកមន្ត្រីរាជការមានចំនួន ១៩នាក់ស្មើនឹង១០.6% និងសិស្សមានម្តាយមន្ត្រីរាជការមានចំនួន ៨នាក់ស្មើនឹង ៤.៤% ហើយសិស្សមានឪពុកមានការងារឯកជនចំនួន ៧នាក់ស្មើនឹង៣.៩% និងសិស្សមានម្តាយការងារឯកជនមានចំនួន ៧នាក់ស្មើនឹង៣.៩% រីឯសិស្សមានឪពុកជាកសិករចំនួន ១៣៧នាក់ស្មើនឹង៧៦.១%

និងសិស្សមានម្ដាយជាកសិករចំនួន ១៤៥នាក់ស្មើនឹង៨០.៦% ខណៈពេលដែលមានអ្នកផ្សេងទៀតគ្មានការងារធ្វើ ឬស្លាប់។

តាមតារាងនេះ បង្ហាញថា ឪពុកម្ដាយសិស្សមានភាគច្រើនជាកសិករ។ ខេត្តត្បូងឃ្មុំជាខេត្តកូនពៅនៃប្រទេសកម្ពុជា ប្រជាជនភាគច្រើនជាកសិករ ធ្វើកសិកម្មដូចជា ធ្វើស្រែ ចម្ការ ដាំដុះដំណាំដំឡូងមីកៅស៊ូ ម្រេច ស្វាយចន្ទីជាដើម។ មានការសិក្សាបានរកឃើញថា ឪពុកម្ដាយដែលមានប្រាក់ចំណូលនិងប្រវត្តិអប់រំពីមធ្យមទៅខ្ពស់ មានជំនឿនិងការរំពឹងទុកតិចជាងគ្រួសារដែលមានចំណូលទាប ទៅលើការអនុវត្តជាក់ស្ដែងចំពោះការសិក្សារបស់កូនៗ។ រីឯគ្រួសារដែលមានចំណូលទាបវិញ មានជំនឿនិងការរំពឹងទុកខ្ពស់ លើដំណើរការសិក្សា ដែលមិនមានទំនាក់ទំនងល្អជាមួយការសិក្សាជាក់ស្ដែងរបស់កូនៗពួកគេនៅក្នុងសាលារៀន (Alexander, Entwisle and Bedinger ,1994) ។

តារាងទី៧៖ លទ្ធផលសិស្សរបស់សិស្ស

| ល.រ | បរិយាយ | ចំនួន | ភាគរយ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | និទ្ទេស A | ២៧ | ១៥ | ល្អប្រសើរ |
| ២ | និទ្ទេស B | ២៦ | ១៤.៤ | ល្អណាស់ |
| ៣ | និទ្ទេស C | ៤៧ | ២៦.១ | ល្អ |
| ៤ | និទ្ទេស D | ២៨ | ១៥.៦ | ល្អបង្គួរ |
| ៥ | និទ្ទេស E | ៣១ | ១៧.២ | មធ្យម |
| ៦ | និទ្ទេស F | ២១ | ១១.៧ | ខ្សោយ |
| សរុប | | ១៨០ | ១០០ | |

តារាងទី៧ បានបង្ហាញថាការឆ្លើយតបរបស់សិស្សនៅមធ្យមសិស្សសិក្សានៅខេត្តត្បូងឃ្មុំ ដែលមានវិទ្យាចំនួន៦ ចំនួន១៨០នាក់ ទៅលើមធ្យមភាគពិន្ទុប្រឡងឆមាសលើកទី១ មានសិស្សនិទ្ទេស A ចំនួន២៧នាក់ ស្មើនឹង១៥% ក្នុងនោះផងដែរមានសិស្ស២១នាក់ប្រឡងបាននិទ្ទេស F ជាកម្រិតខ្សោយស្មើនឹង១១.៧%។

តាមតារាងនេះ សិស្សភាគច្រើនប្រឡងបាននិទ្ទេស C។ លទ្ធផលនេះការសិក្សារបស់សិស្សក្នុងការសិក្សា ពិតជាធ្វើបានក្នុងកម្រិត ល្អ ភាគច្រើន ដែលបង្ហាញពីការប្រឹងប្រែងសិក្សារបស់សិស្ស និងការបង្រៀនរបស់គ្រូ។ ក្នុងនោះផងដែរ ចំពោះសិស្សដែលទទួលបានមធ្យមភាគទាប ពួកគេមានបញ្ហាមួយចំនួនដូចជា ខ្វះថវិកាទៅរៀនបន្ថែម របបម៉ោងរដ្ឋបង្រៀនមានកម្រិត សាលានៅជនបទខ្វះគ្រូបង្រៀន និងបង្រៀនខុសឯកទេស ជួយការងារគ្រួសារធ្វើស្រែចម្ការដោយ ឪពុកម្ដាយសិស្សភាគច្រើនជាកសិករ។

## ៤.២- ការវិភាគទិន្នន័យលើកម្រងសំណួរស្ដីពី ឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេនៅមធ្យមសិក្សាទុតិយភូមិ នៅខេត្តត្បូងឃ្មុំ

ចំណុចនេះអ្នកសិក្សាស្រាវជ្រាវនឹងវិភាគទៅលើមធ្យមភាគ នៃសូចនាករផ្សេងៗ របស់សិស្សានុសិស្ស និងគ្រូបង្រៀន ទៅលើឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេនៅមធ្យមសិក្សាទុតិយភូមិ នៅខេត្តត្បូងឃ្មុំ ដែលមានក្នុងកម្រងសំណួរ។

### ៤.២.១- ឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេនៅមធ្យមសិក្សាទុតិយភូមិ នៅខេត្តត្បូងឃ្មុំ តាមការឆ្លើយតបរបស់សិស្ស

អំពីសិស្សានុសិស្ស អ្នកស្រាវជ្រាវ បានលើកយកចំណុចសំខាន់មួយចំនួន ដើម្បីឱ្យសិស្សឆ្លើយតបក្នុងការស្រាវជ្រាវនេះ។ ចំណុចទាំងនោះរួមមានដូចជា៖ ការគ្រប់គ្រងពេលវេលា ការអាននិងការធ្វើកំណត់ត្រា ការផ្ដោតអារម្មណ៍ កិច្ចការផ្ទះ ការប្រឡង ដើម្បីចង់ដឹងថាចំណុចទាំងនេះមានឥទ្ធិពលបែបណាលើលទ្ធផលរៀនសូត្ររបស់សិស្សនៅមធ្យមសិក្សាទុតិយភូមិនៅខេត្តត្បូងឃ្មុំ។

តារាងទី៨៖ ការគ្រប់គ្រងពេលវេលា

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ខ្ញុំទម្លាប់ចំណាយពេលរៀនសូត្រច្រើនជាងការជជែកគ្នាលេង ឬលេងទូរសព្ទ។ | ៣.១៨ | ០.៩៧ | មធ្យម |
| ២ | ខ្ញុំយល់ឃើញថា ខ្ញុំត្រូវធ្វើការងារសាលាឱ្យបានច្រើន ជាជាងធ្វើកិច្ចការជាច្រើនទៀត។ | ៣.១០ | ១.០០ | មធ្យម |

| | | | | |
|---|---|---|---|---|
| ៣ | ខ្ញុំមិនធ្វេសប្រហែសការងារសាលាទោះមានបញ្ហាជាច្រើននៅក្រៅថ្នាក់រៀនជាមួយសិស្សផ្សេងទៀត ឬនៅផ្ទះក៏ដោយ។ | ៣.២០ | ០.៩៧ | មធ្យម |
| ៤ | ខ្ញុំសិក្សាយ៉ាងហោចណាស់បីម៉ោងក្នុងមួយថ្ងៃបន្ទាប់ពីចេញពីថ្នាក់រៀន។ | ៣.២២ | ១.០៩ | មធ្យម |
| ៥ | ខ្ញុំមិនចំណាយពេលច្រើនពេកលើមុខវិជ្ជាតែមួយមុខ ដើម្បីធ្វើឱ្យខ្ញុំមិនមានពេលគ្រប់គ្រាន់លើមុខវិជ្ជាផ្សេងទៀត។ | ៣.៥០ | ១.០៩ | ល្អ |
| ៦ | ខ្ញុំមិនចំណាយពេលច្រើនពេកក្នុងការអានសៀវភៅផ្សេងៗ ឬទៅដើរលេង ដើម្បីទុកពេលវេលាធ្វើការងារសាលារបស់ខ្ញុំ។ | ៣.៣៧ | ៣.២៨ | មធ្យម |
| សរុប | | ៣.២៦ | ១.៤០ | មធ្យម |

តារាងទី៨ បានបង្ហាញថាការឆ្លើយតបរបស់សិស្សនៅមធ្យមសិស្សសិក្សានៅខេត្តត្បូងឃ្មុំដែលមានវិទ្យាចំនួន ៦ចំនួន ១៨០នាក់ទៅលើការគ្រប់គ្រងពេលវេលាទទួលបាននូវកម្រិតមធ្យម (មធ្យមភាគ=៣.២៦)។ សូចនាករដែលឆ្លើយតបលើការគ្រប់គ្រងពេលវេលា ដែលទទួលបានមធ្យមភាគពិន្ទុខ្ពស់គឺ ការមិនចំណាយពេលច្រើនពេកលើមុខវិជ្ជាតែមួយមុខ ដើម្បីធ្វើឱ្យខ្ញុំមិនមានពេលគ្រប់គ្រាន់លើមុខវិជ្ជាផ្សេង (មធ្យមភាគ=៣.៥) ហើយសូចនាករដែលបានពិន្ទុទាបជាងគេគឺ ខ្ញុំយល់ឃើញថា ខ្ញុំត្រូវធ្វើការងារសាលាឱ្យបានច្រើន ជាជាងធ្វើកិច្ចការជាច្រើនទៀត។

លទ្ធផលការសិក្សានេះ បង្ហាញថាការគ្រប់គ្រងពេលវេលារៀនសូត្រភាគច្រើន មានកម្រិតចង្អុលបង្ហាញ"មធ្យម" (មធ្យមភាគ=៣.២៦) ។ សិស្សមិនទាន់គ្រប់គ្រងពេលវេលារៀនសូត្រនៅមានកម្រិតមិនទាន់ល្អប្រសើរនៅឡើង។ ការបែងចែកពេលវេលាសម្រាប់មុខវិជ្ជាដែលត្រូវសិក្សា អាចឱ្យសិស្សមានផែនការយ៉ាងម៉ត់ចត់ ដើម្បីបំពេញកិច្ចការសិក្សានៅពេលខាងមុខ និងជួយរៀបចំពេលវេលាសម្រាប់ការងារសិក្សា មុនពេលសិស្សចាប់ផ្តើមគិតអំពីដំណើរការនៃការសិក្សា កាលវិភាគត្រូវតែត្រូវបានបង្កើតឡើង (Atkinson ,2003) ។

តារាងទី៩ ៖ការអាន និងការធ្វើកំណត់ត្រា

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ខ្ញុំបានអានសៀវភៅដែលខ្ញុំបានធ្វើការកត់ត្រាក្នុងមេរៀនជាច្រើនដង មុនពេលការប្រឡងចាប់ផ្ដើម។ | ៣.៧៥ | ១.0៣ | ល្អ |
| ២ | បន្ទាប់ពីអានកិច្ចការមួយជាច្រើនទំព័រ ខ្ញុំយល់ថាការកត់ចំណាំធ្វើឱ្យមានភាពងាយស្រួលក្នុងការចងចាំនូវអ្វីដែលខ្ញុំបានអាន។ | ៣.៩២ | 0.៩៥ | ល្អ |
| ៣ | ខ្ញុំយល់ថាមានភាពងាយស្រួលក្នុងការជ្រើសរើសចំណុចសំខាន់ៗ ក្នុងការអានកិច្ចការណាមួយ។ | ៣.៥៣ | ១.0៣ | ល្អ |
| ៤ | ខ្ញុំអានហើយឈប់បន្តិចមុន និងអានបន្តចំពោះកិច្ចការមួយដែលមានច្រើនទំព័រ ហើយខ្ញុំព្យាយាមចងចាំអ្វីដែលខ្ញុំបានអាន។ | ៣.៦១ | 0.៨៩ | ល្អ |
| ៥ | ខ្ញុំត្រូវអានអត្ថបទសារឡើងវិញជាច្រើនដង ពេលខ្ញុំមិនទាន់យល់ន័យពាក្យណាមួយពេល ដែលខ្ញុំអានវាលើកដំបូង។ | ៣.៩២ | 0.៩៧ | ល្អ |
| ៦ | ខ្ញុំមិនមានបញ្ហាក្នុងការជ្រើសរើសចំណុចសំខាន់ៗនៅក្នុងមេរៀនដែលខ្ញុំបានអាន ឬសិក្សា។ | ៣.១0 | ១.0៤ | មធ្យម |
| ៧ | ខ្ញុំស្វ័យសិក្សាដោយខ្លួនឯងនូវមេរៀនដែលខ្ញុំបានរៀនរួចដោយពិនិត្យមើលឡើងវិញនូវចំណុចដែលខ្ញុំមិនទាន់យល់ច្បាស់។ | ៣.៥៩ | ១.0៦ | ល្អ |
| ៨ | ខ្ញុំស្វែងរកចំណុចសំខាន់ៗរបស់មេរៀន ពេលកំពុងកត់ត្រាមេរៀនរួចយកទៅពិភាក្សាជាមួយមិត្តភ័ក្ដ ឬអ្នកនៅជុំវិញខ្លួន។ | ៣.៥១ | ១.0៨ | ល្អ |
| ៩ | ខ្ញុំឈ្វេងយល់អត្ថន័យពាក្យណាមួយដោយខ្លួនខ្ញុំនៅពេលខ្ញុំអាន។ | ៣.៤៥ | ១.0២ | ល្អ |
| ១0 | ខ្ញុំមានទម្លាប់អានសៀវភៅបានច្រើនជាងសៀវភៅដែលគ្រូរបស់ខ្ញុំបានកំណត់សម្រាប់មុខវិជ្ជារបស់គាត់។ | ៣.១0 | 0.៩៥ | មធ្យម |
| សរុប | | ៣.៥៥ | ១.00 | ល្អ |

តារាងទី៩ បានបង្ហាញថាការឆ្លើយតបរបស់សិស្សនៅមធ្យមសិស្សសិក្សានៅខេត្តត្បូងឃ្មុំដែលមានវិទ្យាចំនួន ៦ចំនួន ១៨0នាក់ទៅលើការអាន និងការធ្វើកំណត់ត្រា ទទួលបាននូវកម្រិតល្អ

(មធ្យមភាគ=៣.៥៥)។ សូចនាករដែលឆ្លើយតបលើការអាន និងការធ្វើកំណត់ត្រាដែលបានមធ្យមភាគពិន្ទុខ្ពស់គឺ បន្ទាប់ពីអានកិច្ចការមួយជាច្រើនទំព័រ ខ្ញុំយល់ថាការកត់ចំណាំធ្វើឱ្យមានភាពងាយស្រួលក្នុងការចងចាំនូវអ្វីដែលខ្ញុំបានអាន (មធ្យមភាគ=៣.៩២) ហើយសូចនាករដែល ទទួលបានពិន្ទុទាបជាងគេគឺ ខ្ញុំមានទម្លាប់អានសៀវភៅបានច្រើនជាងសៀវភៅដែលគ្រូរបស់ខ្ញុំបានកំណត់សម្រាប់មុខវិជ្ជារបស់គាត់។

ការការអាន និងការធ្វើកំណត់ត្រាភាគច្រើនមានកម្រិតចង្អុលបង្ហាញ "ល្អ" ។ សិស្សភាគច្រើនមានទម្លាប់ការអាន និងការធ្វើកំណត់ត្រាល្អ ហើយមានសិស្សមួយចំនួនតិចដែលមិនទាន់មានកម្រិតចង្អុលបង្ហាញល្អ បណ្តាលមកពីសាលារៀនភាគច្រើនមិនមានបណ្ណាល័យ កង្វះឯកសារ ឬសៀវភៅមេរៀនផ្សេងទៀតក្នុងការសិក្សាបន្ថែម។

តារាងទី១០ ៖ ការផ្តោតអារម្មណ៍

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ខ្ញុំយល់ឃើញថា ខ្ញុំមានស្មារតីល្អក្នុងការតាំងចិត្តលើមេរៀនពេលកំពុងសិក្សា។ | ៣.៦៥ | ០.៩៣ | ល្អ |
| ២ | ខ្ញុំមានភាពងាយស្រួលក្នុងចងចាំនូវចំណេះដឹង ដែលខ្ញុំបានសិក្សាក្នុងរយៈពេលណាមួយ។ | ៣.២៧ | ០.៩៦ | មធ្យម |
| ៣ | មិនមានការរំខាននៅខាងក្រៅ ដែលរំខានខ្ញុំពេលកំពុងសិក្សា។ | ៣.១១ | ១.១៦ | មធ្យម |
| ៤ | ខ្ញុំផ្តោតការយកចិត្តទុកដាក់ទាំងស្រុងលើការសិក្សាពេលខ្ញុំកំពុងរៀន។ | ៣.៨២ | ៣.០៩ | ល្អ |
| ៥ | ខ្ញុំមិនមានអារម្មណ៍ងងុយគេង ឬគេងរាល់ពេលដែលខ្ញុំកំពុងសិក្សា។ | ២.៩៥ | ១.០៤ | មធ្យម |
| ៦ | ខ្ញុំអាចសិក្សាបានតែនៅកន្លែងមួយ ដែលស្ងប់ស្ងាត់ទាំងស្រុង។ | ៣.៣៥ | ១.១៧ | មធ្យម |
| សរុប | | ៣.៣៦ | ១.៣៩ | មធ្យម |

តារាងទី១០ បានបង្ហាញថាការឆ្លើយតបរបស់សិស្សនៅមធ្យមសិស្សសិក្សានៅខេត្តត្បូងឃ្មុំដែលមានវិទ្យាល័យចំនួន ៦ចំនួននិងសិស្សចំនួន ១៨០នាក់ទៅលើទៅលើការផ្តោតអារម្មណ៍ ទទួលបាននូវ

កម្រិតមធ្យម (មធ្យមភាគ=៣.៣៦)។ ចំពោះសូចនាករដែលឆ្លើយតបលើការផ្តោតអារម្មណ៍ បានមធ្យមភាគពិន្ទុខ្ពស់គឺ ខ្ញុំផ្តោតការយកចិត្តទុកដាក់ទាំងស្រុងលើការសិក្សាពេលខ្ញុំកំពុងរៀន (មធ្យមភាគ=២.៩៥) ហើយសូចនាករដែលឆ្លើយតបទៅលើការផ្តោតអារម្មណ៍ ទទួលបានពិន្ទុទាបជាងគេគឺខ្ញុំមិនមានអារម្មណ៍ងងុយគេង ឬគេងរាល់ពេលដែលខ្ញុំកំពុងសិក្សា។

ការផ្តោតអារម្មណ៍និងការផ្តោតអារម្មណ៍របស់សិស្សក្នុងការសិក្សាទទួលបានការចង្អុលបង្ហាញត្រឹមកម្រិតមធ្យមប៉ុណ្ណោះ។ លទ្ធផលនេះបង្ហាថា ពេលកំពុងសិក្សាសិស្សមានការលំបាក់លើការផ្តោតអារម្មណ៍ បណ្តាលមកពី ការគេងមិនទៀងទាត់ លំហាត់ប្រាណ ទម្លាប់នៃការបរិភោបអាហារ វិធីសាស្ត្របង្រៀនរបស់គ្រូ ការលើកទឹកចិត្តជាដើម។ ក្នុងនោះផងដែរ លោក Atkinson (2003)បានលើកឡើងថា នៅពេលដែលការផ្តោតអារម្មណ៍ និងការយកចិត្តទុកដាក់ត្រូវបានចុះខ្សោយ ការចងចាំរយៈពេលខ្លីមិនអាចផ្ទេរព័ត៌មានទៅការចងចាំរយៈពេលវែងបានទេ។

តារាងទី១១៖ កិច្ចការផ្ទះ

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | នៅពេលដែលមានកិច្ចការផ្ទះច្រើនពេក ឬពិបាក ខ្ញុំនឹងព្យាយាមធ្វើ ឬសិក្សាផ្នែកដែលពិបាកនៃមេរៀននោះ។ | ៣.៤០ | ០.៩៧ | មធ្យម |
| ២ | ប្រសិនបើខ្ញុំអវត្តមានពីថ្នាក់រៀន ខ្ញុំបានខកខានក្នុងការកត់ត្រាមេរៀន បន្ទាប់មកខ្ញុំខ្ចីកំណត់ត្រាមេរៀននោះភ្លាមៗនៅផ្ទះ។ | ៣.៧៨ | ១.១២ | ល្អ |
| ៣ | ទោះបីកិច្ចការនោះដដែលៗ និងគួរឱ្យធុញក៏ដោយ ខ្ញុំនៅធ្វើវារហូតដល់កិច្ចការនោះត្រូវបានបញ្ចប់។ | ៣.៦១ | ១.០៣ | ល្អ |
| ៤ | ខ្ញុំមិនឈប់ក្នុងការធ្វើកិច្ចការសាលា រហូតដល់ពេលកំណត់។ | ៣.៥៨ | ០.៩៨ | ល្អ |
| ៥ | ខ្ញុំធ្វើ និងផ្តល់កិច្ចការផ្ទះរបស់ខ្ញុំគ្រប់ពេលវេលាជូនគ្រូតាមមុខវិជ្ជាតាមកាលកំណត់។ | ៣.៤៧ | ១.០២ | ល្អ |
| ៦ | ខ្ញុំចាប់ផ្តើមធ្វើកិច្ចការភ្លាមៗនៅពេលដែលគ្រូផ្តល់ឱ្យខ្ញុំដោយមិនទុកឱ្យកិច្ចការនៅសល់ច្រើនដំណាលគ្នា។ | ៣.៣៣ | ១.០៨ | មធ្យម |

| | | | | |
|---|---|---|---|---|
| ៧ | ខ្ញុំធ្វើកិច្ចការផ្ទះដែលគ្រូបានដាក់ឱ្យ ដោយត្រូវការជំនួយពីអ្នកដទៃ។ | ៣.០៥ | ១.១១ | មធ្យម |
| | សរុប | ៣.៤៦ | ១.០៤ | ល្អ |

តារាងទី១១ បានបង្ហាញថាការឆ្លើយតបរបស់សិស្សនៅមធ្យមសិក្សានៅខេត្តត្បូងឃ្មុំដែលមាន ៦ វិទ្យាល័យ និងសិស្សចំនួន ១៨០នាក់ ទៅលើកិច្ចការផ្ទះ ទទួលបាននូវកម្រិតល្អ (មធ្យមភាគ=៣.៤៦)។ ចំពោះសូចនាករដែលឆ្លើយតបលើ កិច្ចការផ្ទះ ដែលបានមធ្យមភាគពិន្ទុខ្ពស់គឺ ប្រសិនបើខ្ញុំអវត្តមានពីថ្នាក់រៀន ខ្ញុំបានខកខានក្នុងការកត់ត្រាមេរៀន បន្ទាប់មកខ្ញុំខ្ចីកំណត់ត្រាមេរៀននោះភ្លាមៗនៅផ្ទះ (មធ្យមភាគ=៣.៧៨) ហើយសូចនាករដែលឆ្លើយតបលើ កិច្ចការផ្ទះ ទទួលបានពិន្ទុទាបជាងគេគឺខ្ញុំធ្វើកិច្ចការផ្ទះដែលគ្រូបានដាក់ឱ្យ ដោយត្រូវការជំនួយពីអ្នកដទៃ (មធ្យមភាគ=៣.០៥)។

កិច្ចការផ្ទះ របស់សិស្សក្នុងការសិស្សទទួលបានការចង្អុលបង្ហាញកម្រិត ល្អ។ លទ្ធផលនេះបង្ហាញពីការសិក្សានៅផ្ទះបានល្អរបស់សិស្សលើការធ្វើកិច្ចការនៅផ្ទះ។ អត្ថប្រយោជន៍នៃកិច្ចការផ្ទះនៅកម្រិតមធ្យមសិក្សាគឺដើម្បីជួយសិស្សក្នុងការអភិវឌ្ឍការប្រើប្រាស់ពេលវេលា ការដោះស្រាយបញ្ហាដោយខ្លួនឯង និង ជួយសិស្សបង្កើតអត្ថប្រយោជន៍អំពីការអនុវត្តល្អ និងទម្លាប់សិក្សា រួមទាំងតម្លៃនៃការខិតខំប្រឹងប្រែង និងសមត្ថភាពក្នុងកែកំហុស និងការលំបាក។ ទាក់ទងនឹងបច្ចេកទេសបង្រៀនផ្សេងទៀត កិច្ចការផ្ទះអាចបង្កើតផលវិជ្ជមានយ៉ាងច្រើនដល់ការអនុវត្តរបស់ក្មេងជំទង់នៅសាលា ( Bempechat , 2004)។

តារាងទី១២៖ ការប្រឡង

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ខ្ញុំធ្វើបានពិន្ទុល្អក្នុងការប្រឡង ព្រោះខ្ញុំព្យាយាមគិតឱ្យបានច្បាស់លាស់។ | ៣.៦៣ | ១.០១ | ល្អ |
| ២ | ខ្ញុំមិនមានការភ័យ និងច្របូកច្របល់នៅពេលប្រឡង ដូច្នេះហើយទើបខ្ញុំឆ្លើយសំណួរត្រឹមត្រូវ។ | ៣.៤៩ | ០.៩៥ | ល្អ |
| ៣ | នៅពេលត្រៀមខ្លួនសម្រាប់ការប្រឡង ខ្ញុំរៀបចំកាលវិភាគដើម្បីរៀនតាមលំដាប់លំដោយដែលបានគ្រោងទុក។ | ៣៨៨ | ៣.១៨ | ល្អ |

| | | | | |
|---|---|---|---|---|
| ៤ | ខ្ញុំអាចបញ្ចប់ការប្រឡងក្នុងរយៈពេលដែលបានកំណត់។ | ៣.៦១ | ១.០៣ | ល្អ |
| ៥ | ខ្ញុំបញ្ចប់វិញ្ញាសាប្រឡងរបស់ខ្ញុំ ហើយប្រគល់វាមុនម៉ោងកំណត់ពេលប្រឡង។ | ៣.៣៧ | ១.១១ | មធ្យម |
| សរុប | | ៣.៦០ | ១.៤៦ | ល្អ |

តារាងទី១២ បានបង្ហាញថាការឆ្លើយតបរបស់សិស្សនៅមធ្យមសិក្សានៅខេត្តត្បូងឃ្មុំដែលមាន ៦ វិទ្យាល័យ និងសិស្សចំនួន ១៨០នាក់ទៅលើការប្រឡង ទទួលបាននូវកម្រិតល្អ (មធ្យមភាគ=៣.៦០)។ សូចនាករដែលឆ្លើយតបលើការប្រឡង ទទួលបានមធ្យមភាគពិន្ទុខ្ពស់គឺ នៅពេលត្រៀមខ្លួនសម្រាប់ការប្រឡង ខ្ញុំរៀបចំកាលវិភាគដើម្បីរៀនតាមលំដាប់លំដោយដែលបានគ្រោងទុក (មធ្យមភាគ=៣.៨៨) ហើយសូចនាករទៅលើការប្រឡងដែលបានពិន្ទុទាបជាងគេគឺ ខ្ញុំបញ្ចប់វិញ្ញាសារប្រឡងរបស់ខ្ញុំ ហើយប្រគល់វាមុនម៉ោងពេលប្រឡង (មធ្យមភាគ=៣.៣៧)។

ការប្រឡងរបស់សិស្សក្នុងការវាយតម្លៃលើ ការសិស្សទទួលបានការចង្អុលបង្ហាញកម្រិត ល្អ។ លទ្ធផលនេះបង្ហាញថា សិស្សបានត្រៀមខ្លួនបានល្អនៅក្នុងការប្រឡង។ ការប្រឡងជារង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស។ ជាទូទៅ រង្វាយតម្លៃ អាចវិនិច្ឆ័យលើ គុណភាព ប្រសិទ្ធភាព គុណតម្លៃ និងតម្លៃប្រព័ន្ធកម្មវិធី ផលិតផល និងការអនុវត្តផ្សេងៗ (ក្រសួងអប់រំ យុវជន និងកីឡា ២០១៨)។

### ៤.២.២- លទ្ធផលនៃការសិក្សាស្រាវជ្រាវលើឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេនៅមធ្យមសិក្សាទុតិយភូមិ នៅខេត្តត្បូងឃ្មុំ តាមការឆ្លើយតបរបស់សិស្ស

ចំណុចនេះ អ្នកស្រាវជ្រាវនឹងបង្ហាញពីទិន្នន័យមធ្យមភាគសរុបរួម ទៅលើឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេនៅមធ្យមសិក្សាទុតិយភូមិនៅខេត្តត្បូងឃ្មុំតាមទស្សនៈរបស់សិស្ស ពាក់ព័ន្ធនឹងសូចនាកររួមមានដូចជា៖ ការគ្រប់គ្រងពេលវេលា ការអាននិងការធ្វើកំណត់ត្រា ការផ្តោតអារម្មណ៍ កិច្ចការផ្ទះ ការប្រឡង។

តារាងទី១៣៖ តារាងទិន្នន័យសរុបរបស់សិស្ស

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ការគ្រប់គ្រងពេលវេលា | ៣.២៦ | ១.៤ | មធ្យម |
| ២ | ការអាន និងការធ្វើកំណត់ត្រា | ៣.៥៥ | ១.០០ | ល្អ |
| ៣ | ការផ្តោតអារម្មណ៍ | ៣.៣៦ | ១.៣៩ | មធ្យម |
| ៤ | កិច្ចការផ្ទះ | ៣.៤៦ | ១.០៤ | ល្អ |
| ៥ | ការប្រឡង | ៣.៦ | ១.៤៦ | ល្អ |
| | សរុប | ៣.៤៤ | ១.២៦ | ល្អ |

តារាងទី១៣ បានបង្ហាញថាការឆ្លើយតបរបស់សិស្សនៅមធ្យមសិស្សសិក្សានៅខេត្តត្បូងឃ្មុំដែលមាន ០៦វិទ្យាល័យនិងសិស្សចំនួន ១៨០នាក់ទៅលើការវាយតម្លៃជារួមលើ ការប្រឡង កិច្ចការផ្ទះ ការអាន និងការធ្វើកត់កំណត់ត្រា ការផ្តោតអារម្មណ៍ និងការគ្រប់គ្រងពេលវេលា មានកម្រិតចង្អុលបង្ហាញ ល្អ (មធ្យម=៣.៤៤)។ ក្នុងនោះផងដែរ ការប្រឡង កិច្ចការផ្ទះ ការអាន និងការកត់ចំណាំ មានកម្រិតចង្អុលបង្ហាញ ល្អ។ រីឯការផ្តោតអារម្មណ៍ និងការគ្រប់គ្រងពេលវេលាមានកម្រិតចង្អុលបង្ហាញត្រឹមមធ្យមប៉ុណ្ណោះ ។

សរុបមកដើម្បីឱ្យសិស្ស អភិវឌ្ឍទម្លាប់សិក្សាកាន់តែល្អប្រសើរ ការគ្រប់គ្រងពេលវេលា និងការផ្តោតអារម្មណ៍ជាសូចករដ៏ល្អបំផុត នៃវិសាលភាពដែលទម្លាប់សិក្សារបស់សិស្សមានឥទ្ធិពលលើលទ្ធផលសិក្សារបស់ពួកគេ បើទោះបីជាមានឥទ្ធិពលតិចតួច ឬតិចតួចបំផុត ក្នុងន័យថាលទ្ធផលសិក្សារបស់សិស្សអាស្រ័យ លើចំនួនពេលវេលាដែលសិស្សចំណាយក្នុងការសិក្សា និងការគ្រប់គ្រងសកម្មភាពរៀនសូត្ររបស់ពួកគេ។

### ៤.២.៣- ឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេនៅមធ្យមសិក្សាទុតិយភូមិ នៅខេត្តត្បូងឃ្មុំ តាមការឆ្លើយតបរបស់គ្រូ

ក្នុងចំណុចនេះ អ្នកសិក្សាស្រាវជ្រាវបានផ្តោតលើចំណុចសំខាន់ពាក់ព័ន្ធនឹងគ្រូបង្រៀនដូចជា៖ ការគ្រប់គ្រងពេលវេលា ការអាននិងការធ្វើកំណត់ត្រា ការផ្តោតអារម្មណ៍ កិច្ចការផ្ទះ ការប្រឡង ដើម្បីចង់

ដឹងថាចំណុចទាំងនេះមានឥទ្ធិពលបែបណាលើលទ្ធផលរៀនសូត្ររបស់សិស្សនៅមធ្យមសិក្សាទុតិយភូមិនៅខេត្តត្បូងឃ្មុំ។

តារាងទី១៤៖ ការគ្រប់គ្រងពេលវេលា

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | សិស្សចំណាយពេលរៀនសូត្រច្រើនជាងការលេងទូរសព្ទ ឬជជែកគ្នាលេង។ | ៣.០៧ | ០.៩៧ | មធ្យម |
| ២ | សិស្សមករៀនទៀងទាត់ និងទាន់ពេលវេលា។ | ៣.៩៨ | ១.៤០ | ល្អ |
| ៣ | សិស្សធ្វើកិច្ចការផ្ទះដែលគ្រូបានដាក់ឱ្យ គ្រប់ៗគ្នានិងទាន់ពេលវេលាកំណត់។ | ៣.២៩ | ១.០៨ | មធ្យម |
| ៤ | សិស្សសិក្សាយ៉ាងហោចណាស់បីម៉ោងក្នុងមួយថ្ងៃបន្ទាប់ពីចេញពីថ្នាក់រៀន។ | ៣.២៥ | ១.០៩ | មធ្យម |
| សរុប | | ៣.១៦ | ១.០៣ | មធ្យម |

តារាងទី១៤ បានបង្ហាញថាការឆ្លើយតបរបស់គ្រូបង្រៀន នៅមធ្យមសិស្សសិក្សានៅខេត្តត្បូងឃ្មុំដែលមាន ០៦វិទ្យាល័យនិងគ្រូចំនួន ៥៥នាក់ទៅលើការគ្រប់គ្រងពេលវេលាលើការសិក្សារបស់សិស្សទទួលបាននូវកម្រិតល្អ(មធ្យមភាគ=៣.១៦)។ក្នុងនោះសូចនាករដែលឆ្លើយតបលើការគ្រប់គ្រងពេលវេលាដែលទទួលបានមធ្យមភាគពិន្ទុខ្ពស់គឺ ការមករៀនទៀងទាត់ និងទាន់ពេលវេលា (មធ្យមភាគ=៣.៩៨) ហើយសូចនាករដែលបានពិន្ទុទាបជាងគេគឺ សិស្សចំណាយពេលរៀនសូត្រច្រើនជាងការលេងទូរសព្ទ ឬជជែកគ្នាលេង (មធ្យមភាគ=៣.១៦)។

ការគ្រប់គ្រងពេលវេលារបស់សិស្សទទួលបានការចង្អុលបង្ហាញក្នុងកម្រិត មធ្យម។ លទ្ធផលនេះបង្ហាញថា សិស្សមកសិក្សាទៀងទាត់ និងទាន់ពេលវេលាបានល្អ។ ក្នុងនោះផងដែរ សិស្សមានទម្លាប់សិស្សនៅកម្រិត មធ្យមនៅឡើយលើសូចនាករ សិស្សចំណាយពេលរៀនសូត្រច្រើនជាងការលេងទូរសព្ទ ឬជជែកគ្នាលេង សិស្សធ្វើកិច្ចការផ្ទះដែលគ្រូបានដាក់ឱ្យ គ្រប់ៗគ្នានិងទាន់ពេលវេលាកំណត់ សិស្សសិក្សាយ៉ាងហោចណាស់បីម៉ោងក្នុងមួយថ្ងៃបន្ទាប់ពីចេញពីថ្នាក់រៀន។

តារាងទី១៥៖ការអាន និងការធ្វើកំណត់ត្រា

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | សិស្សមានឥរិយាបទល្អក្នុងការអាន និងកត់ត្រាមេរៀនក្នុងពេលរៀនសូត្រ។ | ៣.៨៩ | ០.៧១ | ល្អ |
| ២ | សិស្សមានទម្លាប់ក្នុងការកត់ត្រាពេលពួកគេអាន អត្ថបទមួយដែលមានច្រើនទំព័រ។ | ៣.៤០ | ០.៨៥ | មធ្យម |
| ៣ | សិស្សមានភាពងាយស្រួលក្នុងការជ្រើសរើសចំណុចសំខាន់ៗ ក្នុងការអានអត្ថបទណាមួយ។ | ៣.៤៩ | ០.៨៥ | ល្អ |
| ៤ | សិស្សព្យាយាមស្វែងយល់មេរៀនដែលពួកគេបានអាន។ | ៣.៤០ | ០.៩៥ | មធ្យម |
| ៥ | សិស្សភាគច្រើនស្វ័យសិក្សាដោយខ្លួនឯងនូវមេរៀនដែលបានរៀនរួច។ | ៣.៣០ | ១.០១ | មធ្យម |
| ៦ | សិស្សតែងតែស្វែងរកចំណុចសំខាន់ៗរបស់មេរៀននៅក្នុងថ្នាក់រៀនដោយខ្លួនឯង ពេលកំពុងកត់ត្រាមេរៀន។ | ៣.១៨ | ០.៨៦ | មធ្យម |
| ៧ | សិស្សឈ្វេងយល់អត្ថន័យអត្ថបទមួយដោយខ្លួនឯង ឬដោយពិភាក្សាជាមួយមិត្តភ័ក្ត។ | ៣.៣៦ | ០.៨៤ | មធ្យម |
| ៨ | សិស្សមានទម្លាប់អានសៀវភៅបានច្រើនជាងសៀវភៅដែលគ្រូបានកំណត់សម្រាប់មុខវិជ្ជាដែលបានរៀន។ | ៣.២៧ | ១.០៦ | មធ្យម |
| សរុប | | ៣.៤១ | ០.៨៩ | ល្អ |

តារាងទី១៥ បានបង្ហាញថាការឆ្លើយតបរបស់គ្រូបង្រៀននៅមធ្យមសិស្សសិក្សានៅខេត្តត្បូងឃ្មុំ ដែលមានចំនួន៦ វិទ្យាល័យនិងគ្រូមានចំនួន ៥៥នាក់ទៅលើការអាន និងការធ្វើកំណត់ត្រា ទទួលបាននូវកម្រិត ល្អ (មធ្យមភាគ=៣.៤១)។ សូចនាករដែលឆ្លើយតបលើការអាន និងការធ្វើកំណត់ត្រាដែលបានមធ្យមភាគពិន្ទុខ្ពស់គឺ សិស្សមានឥរិយាបទល្អក្នុងការអាន និងកត់ត្រាមេរៀនក្នុងពេលរៀនសូត្រ (មធ្យមភាគ=៣.៨៩) ហើយសូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺសិស្សតែងតែស្វែងរកចំណុចសំខាន់ៗរបស់មេរៀននៅក្នុងថ្នាក់រៀនដោយខ្លួនឯង ពេលកំពុងកត់ត្រាមេរៀន (មធ្យមភាគ=៣.១៨)។

ការអាន និងការធ្វើកំណត់ត្រា របស់សិស្សក្នុងការសិស្សទទួលបានការចង្អុលបង្ហាញកម្រិតមធ្យម។ លទ្ធផលនេះបង្ហាញថា ការឆ្លើយតបរបស់គ្រូ លើការអាន និងការធ្វើកំណត់ត្រារបស់សិស្សមានឥរិយាបទល្អក្នុងការអាន និងកត់ត្រាមេរៀនក្នុងពេលរៀនសូត្រ ចំណែកការស្វ័យសិក្សារបស់ពួកគេនៅ

កម្រិតមធ្យមនៅឡើង លើការស្វែងយល់មេរៀន ការរកចំណុចសំខាន់ៗ ក្នុងអត្ថបទ ការអានសៀវភៅដែលគ្រូបានកំណត់ឱ្យចំពោះមេរៀនដែលបានសិក្សា។

តារាងទី១៦៖ ការផ្តោតអារម្មណ៍

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ខ្ញុំយល់ឃើញថាសិស្សភាគច្រើនមានការផ្តោតអារម្មណ៍ខ្លាំងលើមេរៀនពេលកំពុងសិក្សា។ | ៣.៥២ | ០.៨៧ | ល្អ |
| ២ | សិស្សចូលរួមពិភាក្សាក្រុមយ៉ាងសកម្ម ពេលកំពុងសិក្សា។ | ៣.៦៩ | ២.៦៧ | ល្អ |
| ៣ | មានកត្តាខាងក្រៅជាច្រើនដែលជាការរំខានដល់សិស្សពេលកំពុងសិក្សា។ | ៣.២១ | ១.០៣ | មធ្យម |
| ៤ | សិស្សមានឆន្ទៈក្នុងការសិក្សា និងចូលរួមធ្វើសកម្មភាពសិក្សាផ្សេងៗ ដែលគ្រូរៀបចំ។ | ៣.៤៩ | ០.៨៣ | ល្អ |
| ៥ | សិស្សតែងតែមិនមានអារម្មណ៍ងងុយគេងរាល់ពេលដែលកំពុងសិក្សា។ | ៤.០៧ | ៥.៥៨ | ល្អ |
| ៦ | ខ្ញុំយល់ឃើញថាសិស្សភាគច្រើនចូលចិត្តមុខវិជ្ជារបស់ខ្ញុំ។ | ៣.៥២ | ០.៩៣ | ល្អ |
| សរុប | | ៣.៥៨ | ១.៩៨ | ល្អ |

តារាងទី១៦ បានបង្ហាញថាការឆ្លើយតបរបស់គ្រូបង្រៀននៅមធ្យមសិស្សសិក្សាទុតិយភូមិនៅខេត្តត្បូងឃ្មុំដែលមានចំនួន ៦វិទ្យាល័យនិងមានគ្រូចំនួន ៥៥នាក់ទៅលើការផ្តោតអារម្មណ៍របស់សិស្ស ទទួលបាននូវកម្រិតល្អ (មធ្យមភាគ=៣.៥៨)។ ចំពោះសូចនាករដែលឆ្លើយតបលើការផ្តោតអារម្មណ៍ បានមធ្យមភាគពិន្ទុខ្ពស់គឺ សិស្សតែងតែមិនមានអារម្មណ៍ងងុយគេងរាល់ពេលដែលកំពុងសិក្សាខ្ញុំ (មធ្យមភាគ=៤.០៧) ហើយសូចនាករដែលឆ្លើយតបទៅលើការផ្តោតអារម្មណ៍ ទទួលបានពិន្ទុទាបជាងគេគឺ មានកត្តាខាងក្រៅជាច្រើនដែលជាការរំខានដល់សិស្សពេលកំពុងសិក្សា (មធ្យមភាគ=៣.២១) ។

ការផ្តោតអារម្មណ៍របស់សិស្ស ក្នុងការសិស្សទទួលបានការចង្អុលបង្ហាញកម្រិត ល្អ។ លទ្ធផលនេះបង្ហាញថា សិស្សមានការគ្រប់គ្រងអារម្មណ៍មានល្អ និងចូលរួមយ៉ាងសកម្មក្នុងពេលកំពុងសិក្សា ហើយមានកត្តារំខានបន្តិចបន្តួចពីខាងក្រៅ។

តារាងទី១៧៖ កិច្ចការផ្ទះ

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | សិស្សព្យាយាមធ្វើកិច្ចការផ្ទះ ដែលគ្រូបានដាក់ឱ្យគ្រប់ៗគ្នា និងយ៉ាងទៀងទាត់។ | ៣.៥០ | ១.០៣ | ល្អ |
| ២ | សិស្សចាប់ផ្តើមធ្វើកិច្ចការភ្លាមៗនៅពេលដែលគ្រូផ្តល់ឱ្យ ដោយមិនទុកឱ្យកិច្ចការនៅសល់ច្រើនជំណាលគ្នា។ | ៣.៣៦ | ១.០២ | មធ្យម |
| ៣ | សិស្សធ្វើកិច្ចការផ្ទះដែលគ្រូបានដាក់ឱ្យ ដោយត្រូវការជំនួយពីអ្នកដ៏ទៃ។ | ៤.១២ | ៥.៥៤ | ល្អ |
| សរុប | | ៣.៦៦ | ២.៥៣ | ល្អ |

តារាងទី១៧ បានបង្ហាញថាការឆ្លើយតបរបស់គ្រូបង្រៀននៅមធ្យមសិស្សសិក្សានៅខេត្តត្បូងឃ្មុំ ដែលមានចំនួន ៦វិទ្យាល័យនិងគ្រូចំនួន ៥៥នាក់ទៅលើការធ្វើកិច្ចការផ្ទះរបស់សិស្ស ទទួលបាននូវកម្រិតល្អ (មធ្យមភាគ=៣.៦៦)។ ចំពោះសូចនាករដែលឆ្លើយតបលើ កិច្ចការផ្ទះ ដែលបានមធ្យមភាគពិន្ទុខ្ពស់គឺ សិស្សធ្វើកិច្ចការផ្ទះដែលគ្រូបានដាក់ឱ្យ ដោយមិនត្រូវការជំនួយពីអ្នកដ៏ទៃ (មធ្យមភាគ=៤.១២) ហើយសូចនាករដែលឆ្លើយតបលើ កិច្ចការផ្ទះ ទទួលបានពិន្ទុទាបជាងគេគឺសិស្សចាប់ផ្តើមធ្វើកិច្ចការភ្លាមៗនៅពេលដែលគ្រូផ្តល់ឱ្យ ដោយមិនទុកឱ្យកិច្ចការនៅសល់ច្រើនជំណាលគ្នា (មធ្យមភាគ=៣.៣៦) ។

កិច្ចការផ្ទះ របស់សិស្សក្នុងការសិស្សទទួលបានការចង្អុលបង្ហាញកម្រិត ល្អ។ លទ្ធផលនេះបង្ហាញថា សិស្សបានធ្វើកិច្ចការផ្ទះ ដែលគ្រូបានដាក់ឱ្យបានល្អ និងមិនសូវត្រូវការជំនួយពីអ្នកដទៃ ប៉ុន្តែពួកគេបានទុកកិច្ចការផ្ទះនៅសល់ច្រើនជំណាលគ្នាមុខនិងបញ្ចប់រួចប្រគល់ជូនគ្រូបង្រៀន។

តារាងទី១៨៖ ការប្រឡង

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | សិស្សភាគច្រើនត្រៀមខ្លួនបានល្អសម្រាប់ការប្រឡង ដោយរៀបចំកាលវិភាគដើម្បីរៀនតាមលំដាប់លំដោយដែលបានគ្រោងទុក។ | ៣.៥៨ | ០.៨៥ | ល្អ |
| ២ | ទម្លាប់សិក្សាប្រចាំថ្ងៃទៀងទាត់ជួយសិស្សទទួលបានពិន្ទុខ្ពស់ក្នុងការប្រឡង។ | ៣.៨៥ | ០.៨០ | ល្អ |

| | | | | |
|---|---|---|---|---|
| ៣ | សិស្សភាគច្រើនបានបញ្ចប់ដំណើរការសំណេរក្នុងការប្រឡងក្នុងរយៈពេលដែលបានកំណត់។ | ៣.៤៧ | ១.០៣ | ល្អ |
| សរុប | | ៣.៦៣ | ០.៨៩ | ល្អ |

តារាងទី១៩ បានបង្ហាញថាការឆ្លើយតបរបស់គ្រូបង្រៀន នៅមធ្យមសិស្សសិក្សានៅខេត្តត្បូងឃ្មុំ ដែលមានចំនួន ៦វិទ្យាល័យនិងគ្រូចំនួន ៥៥នាក់ទៅលើការប្រឡងរបស់សិស្ស ទទួលបាននូវកម្រិត ល្អ (មធ្យមភាគ=៣.៦៣)។ សូចនាករដែលឆ្លើយតបលើការប្រឡង ទទួលបានមធ្យមភាគពិន្ទុខ្ពស់គឺ ទម្លាប់សិក្សាប្រចាំថ្ងៃទៀងទាត់ជួយសិស្សទទួលបានពិន្ទុខ្ពស់ក្នុងការប្រឡង (មធ្យមភាគ=៣.៨៥) ហើយសូចនាករទៅលើការប្រឡងដែលបានពិន្ទុទាបជាងគេគឺ សិស្សភាគច្រើនបានបញ្ចប់ដំណើរការសំណេរក្នុងការប្រឡងក្នុងរយៈពេលដែលបានកំណត់ (មធ្យមភាគ=៣.៤៧) ។

ការប្រឡង របស់សិស្សក្នុងការសិស្សទទួលបានការចង្អុលបង្ហាញកម្រិត ល្អ។ លទ្ធផលនេះ បង្ហាញថា សិស្សមានការសិក្សាជាប្រចាំថ្ងៃទៀងទាត់ និងមានការរៀបចំខ្លួនបានល្អសម្រាប់ការប្រឡង និងបានបញ្ចប់សំណេររបស់ពួកគេតាមការកំណត់ក្នុងពេលប្រឡងបានយ៉ាងល្អ។

### ៤.២.៤- លទ្ធផលនៃការសិក្សាស្រាវជ្រាវលើឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេនៅមធ្យមសិក្សាទុតិយភូមិ នៅខេត្តត្បូងឃ្មុំ តាមការឆ្លើយតបរបស់គ្រូ

ចំណុចនេះ អ្នកស្រាវជ្រាវនឹងបង្ហាញពីទិន្នន័យមធ្យមភាគសរុបរួម ទៅលើឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេនៅមធ្យមសិក្សាទុតិយភូមិ នៅខេត្តត្បូងឃ្មុំ តាមទស្សនៈរបស់សិស្ស ពាក់ព័ន្ធនឹងសូចនាកររួមមានដូចជា៖ ការគ្រប់គ្រងពេលវេលា ការអាន និងការធ្វើកំណត់ត្រា ការផ្តោតអារម្មណ៍ កិច្ចការផ្ទះ ការប្រឡង។

តារាងទី១៩ ៖ តារាងទិន្នន័យឆ្លើយតបសរុបរបស់គ្រូ

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ការគ្រប់គ្រងពេលវេលា | ៣.១៦ | ១.០៣ | មធ្យម |
| ២ | ការអាន និងការធ្វើកំណត់ត្រា | ៣.៤១ | ០.៨៩ | ល្អ |
| ៣ | ការផ្តោតអារម្មណ៍ | ៣.៥៨ | ១.៩៨ | ល្អ |

| | | | | |
|---|---|---|---|---|
| ៤ | កិច្ចការផ្ទះ | ៣.៦៦ | ២.៥៣ | ល្អ |
| ៥ | ការប្រឡង | ៣.៦៣ | ០.៨៩ | ល្អ |
| | សរុប | ៣.៤៩ | ១.៤៦ | ល្អ |

តារាងទី១៩ បានបង្ហាញថាការឆ្លើយតបរបស់គ្រូបង្រៀន នៅមធ្យមសិស្សសិក្សានៅខេត្តត្បូងឃ្មុំ ទទួលបាននូវកម្រិត ល្អ(មធ្យមភាគ=៣.៤៩)។ សូចនាករដែលឆ្លើយតបទៅលើឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់សិស្សមធ្យមសិក្សាទុតិយភូមិ នៅខេត្តត្បូងឃ្មុំ ដែលទទួលបានមធ្យមភាគពិន្ទុខ្ពស់គឺ សិស្សធ្វើកិច្ចការផ្ទះដែលគ្រូបានដាក់ឱ្យស្ថិតនៅកម្រិតល្អ(មធ្យមភាគ=៣.៦៦) ហើយសូចនាករដែលបានពិន្ទុទាបជាងគេគឺ ការគ្រប់គ្រពេលវេលាស្ថិតនៅកម្រិត មធ្យម (មធ្យមភាគ=៣.១៦) ក្នុងនោះផងដែរ ការអាន និងការធ្វើកំណត់ត្រា ការផ្តោតអារម្មណ៍ និងការប្រឡងស្ថិតនៅកម្រិតល្អដូចគ្នា ។

ជារួមទម្លាប់សិក្សារបស់សិស្សក្នុងការសិស្សទទួលបានការចង្អុលបង្ហាញកម្រិត ល្អ។លទ្ធផលនេះបង្ហាញថា សិស្សមានទម្លាប់សិស្សជាវិជ្ជមានលើសូចនាករ ការអាននិងការធ្វើកំណត់ត្រា ការផ្តោតអារម្មណ៍ កិច្ចការផ្ទះ និងការប្រឡង។ រីឯសូចនាករ ការគ្រប់គ្រងពេលវេលា នៅមិនទាន់មានភាពល្អប្រសើរនៅឡើង និងជាផលជះលើលទ្ធផលសិក្សារបស់សិស្ស។

## ៤.៣-ការពិភាក្សាលើ ឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេនៅមធ្យមសិក្សាទុតិយភូមិ នៅខេត្តត្បូងឃ្មុំ

ចំណុចនេះ អ្នកស្រាវជ្រាវនឹងបង្ហាញពីទិន្នន័យមធ្យមភាគសរុបរួម ទៅលើឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេនៅមធ្យមសិក្សាទុតិយភូមិ នៅខេត្តត្បូងឃ្មុំ តាមទស្សនៈរបស់សិស្ស និង ទស្សនៈរបស់គ្រូ ពាក់ព័ន្ធនឹងសូចនាកររួមមានដូចជា៖ ការគ្រប់គ្រងពេលវេលា ការអាន និងការធ្វើកំណត់ត្រា ការផ្តោតអារម្មណ៍ កិច្ចការផ្ទះ ការប្រឡង។

តារាងទី២០ ៖ តារាងទិន្នន័យឆ្លើយតបសរុបរបស់សិស្ស និងគ្រូបង្រៀន

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ការគ្រប់គ្រងពេលវេលា | ៣.២១ | ១.២១ | មធ្យម |
| ២ | ការអាន និងការធ្វើកំណត់ត្រា | ៣.៤៨ | ០.៩៤ | ល្អ |

| | | | | |
|---|---|---|---|---|
| ៣ | ការផ្តោតអារម្មណ៍ | ៣.៤៧ | ១.៦៨ | ល្អ |
| ៤ | កិច្ចការផ្ទះ | ៣.៥៦ | ១.៧៨ | ល្អ |
| ៥ | ការប្រឡង | ៣.៦១ | ១.១៧ | ល្អ |
| | សរុប | ៣.៤៦ | ១.៣៦ | ល្អ |

តារាងទី២០ បានបង្ហាញថាការឆ្លើយតបរបស់សិស្ស និងគ្រូបង្រៀន នៅមធ្យមសិស្សសិក្សានៅខេត្តត្បូងឃ្មុំ ទទួលបាននូវកម្រិតល្អ(មធ្យមភាគ=៣.៤៦)។

ឆ្លងតាមលទ្ធផលសិក្សាស្រាវជ្រាវ នៃសំណួរស្រាវជ្រាវទី១ ដែលសង្កត់ធ្ងន់ឥទ្ធិពលនៃទម្លាប់សិក្សាលើលទ្ធផលរៀនសូត្រនៅមធ្យមសិក្សាទុតិយភូមិ ករណីសិក្សាក្នុងខេត្តត្បូងឃ្មុំ បានបង្ហាញថាសូចនាករដែលឆ្លើយតបទៅលើឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់សិស្សមធ្យមសិក្សាទុតិយភូមិ នៅខេត្តត្បូងឃ្មុំ ស្ថិតនៅកម្រិតល្អ ដោយ (មធ្យម=៣.៤៦)។ ក្នុងនោះផងដែរមានភាពប្រសើរលើសូចនាករមួយចំនួន និងមានសូចករមួយចំនួនទៀតនៅមានកម្រិត តាមរយៈតម្លៃមធ្យមដែលមានមធ្យមភាគខ្ពស់ និងតម្លៃមធ្យមដែលមានមធ្យមភាគពិន្ទុទាប។

តាមការឆ្លើតតបរវាងគ្រូបង្រៀន និងសិស្សានុសិស្សបានបង្ហាញថាសូចនាករនៃ ការអាន និងការធ្វើកំណត់ត្រា ការផ្តោតអារម្មណ៍ កិច្ចការផ្ទះ ការប្រឡង ស្ថិតនៅកម្រិតចង្អុលបង្ហាញល្អប្រហាក់ប្រហែលគ្នា។ រីឯសូចនាករនៃការគ្រប់គ្រងពេលវេលា មានកម្រិត ចង្អុលបង្ហាញនៅកម្រិត មធ្យមនៅឡើយ។ លទ្ធផលបានបានបង្ហាញថាពិតជាមានសារៈសំខាន់ទាក់ទងនិងលទ្ធផលសិក្សារបស់សិស្ស។

ជារួមសិស្សមានទម្លាប់ល្អក្នុងការសិក្សាក្នុងនោះផងដែរ ការគ្រប់គ្រងពេលវេលាដែលសិស្សចំណាយក្នុងការសិក្សាគួរត្រូវពង្រឹងបន្ថែម ពីគ្រប់ភាគីពាក់ព័ន្ធដើម្បី កែលម្អលទ្ធផលសិក្សារបស់ពួកគេ។

ដើម្បីគាំទ្រដល់ការរកឃើញខាងលើ Atkinson (2003) បានសង្កេតឃើញថា ការបែងចែកពេលវេលាសម្រាប់អ្វីដែលត្រូវសិក្សា អាចឱ្យសិស្សមានផែនការយ៉ាងប្រុងប្រយ័ត្ន ដើម្បីគ្របដណ្តប់កិច្ចការសិក្សានៅខាងមុខ និងជួយរៀបចំពេលវេលាសម្រាប់ការងារសិក្សាផងដែរ។ មុនពេលសិស្សចាប់ផ្តើមគិតអំពីដំណើរការនៃ ការសិក្សា កាលវិភាគត្រូវតែត្រូវបានបង្កើតឡើង។ ការសិក្សាក៏បានបង្ហាញផងដែរថាចំនួនម៉ោង

ដែលសិស្សរៀននៅផ្ទះគឺទាក់ទងទៅនឹងកម្រិតសិក្សារបស់ពួកគេ។ ពេលវេលាគឺជាសូចនាករដ៏សំខាន់សម្រាប់ការសិក្សាប្រកបដោយប្រសិទ្ធភាពនៅកម្រិតវិទ្យាល័យ។ រយៈពេលនៃការសិក្សាគឺជាការពិចារណាយ៉ាងសំខាន់លើរបស់សមត្ថភាពរបស់សិស្សក្នុងការគ្រប់គ្រងពេលវេលារបស់គាត់ និងប្រឈមដោះស្រាយនឹងបញ្ហានៃការសិក្សាដែលរំពឹងទុក។ Bradley (1999) ក្នុងការគាំទ្រការរកឃើញនេះ បានរកឃើញថាសិស្សដែលមានលទ្ធផលការងារខ្ពស់បំផុតមានទំនាក់ទំនងជាវិជ្ជមានជាមួយសកម្មភាពសាលារបស់ពួកគេ ហើយក៏មានអាកប្បកិរិយា និងអនុវត្តការសិក្សាតាមគ្រូបង្រៀនរបស់ពួកគេដែរ ចំណែកឯសិស្សដែលមានលទ្ធផលការងារទាបមានអាកប្បកិរិយា និងខុសគ្នានឹងការបង្រៀនរបស់គ្រូពួកគេ។ នេះពិតជាដាក់បញ្ហាប្រឈមជាច្រើនដល់សិស្សានុសិស្សក្នុងការសិក្សា និងអនុវត្តបានប្រសើរជាងនៅក្នុង សាលា។

ការរកឃើញនេះគឺស្របជាមួយនឹងការសិក្សាពិសោធន៍ ដែលបានរាយការណ៍ដោយ Van Rossum and Schenk (1984)។ អ្នកស្រាវជ្រាវបានសុំឱ្យនិស្សិតមហាវិទ្យាល័យសិក្សាវគ្គប្រវត្តិសាស្ត្រ។ សិស្សដែលទទួលបានពិន្ទុខ្ពស់លើមាត្រដ្ឋានកំណត់ មានប្រហែលពាក់កណ្តាលនៃគំរូ Van Rossum និង Schenk បានព្យាយាមទន្ទេញមាតិកា ដូច្នេះពួកគេអាចផលិតវាឡើងវិញបាន។ អ្នកផ្សេងទៀត ដូចជាអ្នកដែលទទួលបានពិន្ទុខ្ពស់លើមាត្រដ្ឋានចង់ដឹងចង់ឃើញ បានព្យាយាមស្វែងយល់អំពីសម្ភារៈ អភិវឌ្ឍការយល់ដឹង និងគិតអំពីរបៀបដែលព័ត៌មានអាចត្រូវបានប្រើប្រាស់ (ឧទាហរណ៍ ដំណើរការ "កម្រិតស៊ីជម្រៅ")។ មិនគួរឱ្យភ្ញាក់ផ្អើលទេ សិស្សនៅក្នុងក្រុមទាំងពីរបានធ្វើបានល្អស្មើគ្នាលើសំណួរសាកល្បងនៃធម្មជាតិពិត។ ប៉ុន្តែអ្នកដែលសិក្សា "កម្រិតខ្លាំង" ដូចជាប្រធានបទចង់ដឹងចង់ឃើញធ្វើបានល្អជាងលើសំណួរដែលទាមទារ "ការយល់ដឹង" ។ វាទំនងជាសិស្សបានជួបប្រទះវគ្គសិក្សាដែលទាមទារការផលិតប្រកបដោយការយល់ដឹង។ អ្នកដែលជាអ្នកសិក្សាកម្រិតខ្លាំង (ឧទាហរណ៍មានការចង់ដឹងច្រើន) គួរតែទទួលបានពិន្ទុល្អជាង។ ជំនាញសិក្សាដូចជាការមើលជាមុនជាប្រព័ន្ធ ការសូត្រចំណងជើងរង ការអានឡើងវិញក្នុងគោលបំណងស្វែងរកព័ត៌មានលម្អិតសំខាន់ៗក្នុងការគាំទ្រគំនិតសំខាន់ៗ ការអានឡើងវិញនូវចំណងជើងរង និងការ ស្តាប់ ឡើងវិញ។ ព័ត៌មាន ប្រហែលជាជួយសម្រួលដល់ដំណើរការសិក្សារបស់និស្សិតមហាវិទ្យាល័យ។ ពួកគេពិតជាជួយសិស្សក្មេងៗធ្វើបានល្អជាងក្នុងសាលា។ ទោះជា

យ៉ាងណាក៏ដោយ លទ្ធផលផ្សេងទៀត (និងអ្នកផ្សេងទៀត) ណែនាំថា វិធីសាស្ត្របែបនេះមិនគួរត្រូវបាន អនុវត្តដោយមិនដឹងខ្លួនទេ ហើយពួកគេអាចធ្វើវាបានយ៉ាងងាយ។ សំខាន់ជាងនេះទៅទៀត ពួកគេមិន អាចជំនួសការប៉ុនប៉ងដ៏ធ្ងន់ធ្ងរមួយដើម្បីស្វែងយល់អំពីប្រធានបទនៅកម្រិតកាន់តែស៊ីជម្រៅនោះទេ។ ដូច្នេះកម្រិតសិក្សារបស់សិស្សកាន់តែខ្ពស់ នោះម៉ោងកាន់តែច្រើនត្រូវចំណាយលើការសិក្សានៅផ្ទះដើម្បី បង្កើនប្រសិទ្ធភាពសិក្សា។ ការសិក្សាភាគច្រើនត្រូវបានធ្វើឡើងក្នុងអំឡុងពេលថ្ងៃ និងធ្វើកិច្ចការនៅពេល យប់ ២-៤ ម៉ោង។ មិនតែប៉ុណ្ណោះ ការរកឃើញនៃការស្រាវជ្រាវនេះ បង្ហាញថា ទម្លាប់សិក្សាកាន់តែល្អ លទ្ធផលសិក្សាកាន់តែខ្ពស់។

## ៤.៤- ការវិភាគទិន្នន័យលើកម្រងសំណួរស្តីពី ការប្រៀបធៀបឥទ្ធិពលនៃទម្លាប់សិក្សា របស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេផ្អែកតាមភេទ និងកម្រិតថ្នាក់ សិក្សា

### ៤.៤.១- ប្រៀបធៀបឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ ពួកគេផ្អែកតាមភេទ

តារាងទី២១៖ ប្រៀបធៀបឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេ ផ្អែកតាមភេទ

| ល.រ | បរិយាយ | ប្រុស | | ស្រី | | t | P-value |
|---|---|---|---|---|---|---|---|
| | | M | S.D | M | S.D | | |
| ១ | ការគ្រប់គ្រងពេលវេលា | ៣.៣០ | ១.៦៧ | ៣.២៣ | ០.៩៧ | ០.១៣ | **០.៥៨*** |
| ២ | ការអាន និងការធ្វើកំណត់ត្រា | ៣.៤៧ | ១.០៦ | ៣.៦២ | ០.៩៣ | ០.៩៨ | **០.២៨*** |
| ៣ | ការផ្តោតអារម្មណ៍ | ៣.២៨ | ១.១១ | ៣.៤៣ | ១.៥៣ | ៣.៤៣ | **១.៥៣*** |
| ៤ | កិច្ចការផ្ទះ | ៣.៤០ | ១.០៨ | ៣.៥១ | ១.០១ | ០.៧១ | **០.៤៧*** |
| ៥ | ការប្រឡង | ៣.៥៧ | ១.៧៤ | ៣.៦២ | ១.០០ | ០.៧៧ | **០.៣៣*** |

*P >0.0៥

តារាងទី២១ ការប្រៀបធៀបឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្រ របស់ពួកគេផ្អែកតាមភេទ លទ្ធផលសិក្សាស្រាវជ្រាវបានបង្ហាញថា មានភាពប្រហាក់ប្រហែលគ្នារវាងសិស្ស

ប្រុសនិងសិស្សស្រីទៅលើទម្លាប់សិក្សាពួកគេ ដោយផ្អែកលើផ្អែកលើស្ថិតិយ៉ាងមានសារៈសំខាន់ក្នុងកម្រិត *P >0.0៥ ។

### ៤.៤.២- ប្រៀបធៀបឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេផ្អែកតាមកម្រិតថ្នាក់សិក្សា

សិក្សាទៅលើពិន្ទុធមាសទី១របស់សិស្សរៀនថ្នាក់ទី១០ ១១ និង១២នៃវិទ្យាល័យទាំង៦របស់ខេត្តត្បូងឃ្មុំ។

តារាងទី២២៖ ប្រៀបធៀបឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេផ្អែកតាមកម្រិតថ្នាក់សិក្សា

| លក្ខណៈ | ថ្នាក់ទី ១០ | ថ្នាក់ទី១១ | ថ្នាក់ទី១២ | F-Cal | Probability |
|---|---|---|---|---|---|
| ចំនួន | ៦០ | ៦០ | ៦០ | 1.747 | 0.177 |
| មធ្យម | 34.42 | 33.98 | 36.67 | | |
| គម្លាតគំរូ | 7.49 | 9.82 | 7.88 | | |

អថេរមិនអាស្រ័យ៖ លទ្ធផលធមាសទី១
អថេរអាស្រ័យ៖ កម្រិតថ្នាក់ទី ១០ ១១ និង១២

**បំណកស្រាយ**

តារាងទី២២ខាងលើ បានបង្ហាញឱ្យឃើញថាការសិក្សារបស់សិស្សថ្នាក់ទី១០ ១១ និង១២ នៃវិទ្យាល័យទាំង៦មានកម្រិតសិក្សាប្រហាក់ប្រហែលគ្នា ដោយផ្អែកលើតម្លៃមធ្យមនៃកម្រិតថ្នាក់ទាំងបី។

## ៤.៥- លទ្ធផលនៃការវិភាគទិន្នន័យលើកម្រងសំណួរស្តីពី ការប្រៀបធៀបឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេផ្អែកតាមភេទ និងកម្រិតថ្នាក់សិក្សា

### ៤.៥.១- ប្រៀបធៀបឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេផ្អែកតាមភេទ

នៅក្នុងការសិក្សានេះ ការរកឃើញការសិក្សារបស់សិស្សទាំងពីរភេទ មានលក្ខណៈល្អប្រហាក់ប្រហែលគ្នា។ នេះបញ្ជាក់ថា អ្នកឆ្លើយសំណួរជាសិស្សប្រុស និងសិស្សស្រីមានភាពប្រហាប្រហែលគ្នា

ទាក់ទងនឹងអាកប្បកិរិយារបស់ពួកគេចំពោះការអភិវឌ្ឍទម្លាប់សិក្សា។ ប៉ុន្តែបើពិនិត្យមើលជាក់លាក់ក្នុងការប្រៀបធៀបសូចនាករនីមួយៗ ចំពោះការគ្រប់គ្រង់ពេលវេលាសិស្សប្រុសមានការគ្រប់គ្រងពេលវេលាបានល្អជាង(មធ្យម=៣.៣០) សិស្សស្រី (មធ្យម=៣.២៣) រីឯការការអាន និងការធ្វើកំណត់ត្រាសិស្សស្រីធ្វើបានល្អជាង(មធ្យម=៣.៦២) សិស្សប្រុស (មធ្យម=៣.៤៧) ចំណែកឯការផ្តោតអារម្មណ៍សិស្សស្រីមានការផ្តោតអារម្មណ៍ល្អជាង (មធ្យម=៣.៤៣) សិស្សប្រុស (មធ្យម=៣.២៨) ហើយការធ្វើកិច្ចការផ្ទះសិស្សស្រីមានភាពប្រសើរជាង (មធ្យម=៣.៥១) សិស្សប្រុស (មធ្យម=៣.៤០) និងការប្រឡងសិស្សក៏នៅតែធ្វើបានល្អជាង(មធ្យម=៣.៦២) សិស្សប្រុស(មធ្យម=៣.៥៧)។

លទ្ធផលនេះបង្ហាញថា សិស្សស្រីមានទម្លាប់សិក្សាល្អជាងសិស្សប្រុសបន្តិចប៉ុណ្ណោះទៅលើ ការអាន និងការធ្វើកំណត់ត្រា ការផ្តោតអារម្មណ៍ កិច្ចការផ្ទះ និងការប្រឡង។ ហើយសិស្សទាំងពីរភេទមានការគ្រប់គ្រងពេលវេលានៅកម្រិតមធ្យមដូចគ្នា។ ការរកឃើញនេះស្រដៀងគ្នានឹងការរកឃើញរបស់អង្គការយូនីសេហ្វកម្ពុជា (២០២០) ដែរ។ សិស្សប្រុសត្រូវបានចាត់ទុកថាមានឥរិយាបទមិនល្អច្រើនជាងសិស្សស្រី។ អង្គការយូនីសេហ្វកម្ពុជា (២០២០) ក៏បានរកឃើញដែលថា សិស្សស្រីធ្វើកិច្ចការសាលាបានល្អជាងសិស្សប្រុស ព្រោះសិស្សស្រីមិនដើរលេង និងមិនសូវលេងដូចសិស្សប្រុស និងក្នុងការសិក្សាសិស្សស្រីងាយស្រួលប្រដៅជាងសិស្សប្រុស។ ស្របគ្នានេះផងដែរតាមការរកឃើញរបស់ Nori (2002) លទ្ធផលសិក្សាគឺស្ត្រីល្អជាងបុរស។ ដូច្នេះភាពខុសគ្នានៃភេទរបស់សិស្សមានឥទ្ធិពលលើអាកប្បកិរិយារបស់សិស្សចំពោះទម្លាប់សិក្សា និងអាកប្បកិរិយាក្នុងការសិក្សា។ យោងតាមលោក Bower បុគ្គលម្នាក់អាចផ្លាស់ប្តូរអាកប្បកិរិយាសិក្សា តាមរយៈការកែប្រែ ការលើកទឹកចិត្ត និងការពង្រឹងសកម្មភាព។

ជារួមមកតាមការស្រាវជ្រាវនេះ ទោះមានភាពប្រហាក់ប្រហែលគ្នារវាងទម្លាប់សិស្សរបស់សិស្សទាំងពីរភេទក៏ពិតមែន តែសិស្សស្រីមានទម្លាប់សិក្សាប្រសើរជាងសិស្សប្រុសបន្តិត ដែលអាចបង្ហាញពីសមភាពយេនឌ័រ និងបរិយាប័ន្នសិក្សារបស់សិស្សនៅខេត្តត្បូងឃ្មុំទទួលបានលទ្ធផលល្អស្របតាមគោលនយោបាយអប់រំផងដែរ។

### ៤.៥.២- ប្រៀបធៀបឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេផ្អែកតាមកម្រិតថ្នាក់

លទ្ធផលនៃការស្រាវជ្រាវបានបង្ហាញថា មានភាពប្រហាក់ប្រហែលគ្នារវាងសិស្សថ្នាក់ទី ១០ ១១ និង១២នេះមានន័យថា វាមិនមានទំនាក់ទំនងយ៉ាងសំខាន់រវាងកម្រិតថ្នាក់រៀនរបស់សិស្ស និងទម្លាប់សិក្សារបស់ពួកគេទេ។ នេះគឺដោយសារតែមិនមាននភាពខុសប្លែកគ្នានៅក្នុងមធ្យមភាគពិន្ទុ សម្រាប់ទាំងទាំងបីកម្រិតថ្នាក់ នៅក្នុងវិមាត្រនៃទម្លាប់សិក្សារបស់ពួកគេ។ ក្នុងនោះផងដែរកម្រិតថ្នាក់កាន់តែខ្ពស់បានបង្ហាញ អាយុសិស្សកាន់តែច្រើន ដែលការសិក្សាជាច្រើនបានរកឃើញថាវាជាកត្តាសំខាន់ក្នុងការរៀនសូត្ររបស់សិស្ស។ អាយុគឺជាការចង្អុលបង្ហាញនៃភាពចាស់ទុំ និងដែលជួយដល់ការរៀនសូត្ររបស់សិស្ស។ ការពន្យល់នេះត្រូវបានគាំទ្រដោយការងាររបស់អ្នកស្រាវជ្រាវពីមុន (Waldman, 1986; Sturman , 2003; and Kumar,2002) ដែលបានរកឃើញទំនាក់ទំនងវិជ្ជមានកម្រិតមធ្យមរវាងអាយុ និងការសិក្សា។ កត្តាអាយុត្រូវបានបង្ហាញថាមានសារៈសំខាន់ក្នុងការពន្យល់ពីលទ្ធផលសិក្សារបស់សិស្ស ហើយអាយុក៏បានបង្ហាញឡើងជាអថេរពន្យល់ក្នុងការអភិវឌ្ឍទម្លាប់សិក្សាក្នុងចំណោមសិស្ស។ នៅពេលដែលសិស្សកាន់តែចាស់ ពួកគេធ្វើបានល្អក្នុងការសិក្សារបស់ពួកគេ។

ជារួមក្នុងការស្រាវជ្រាវនេះអ្នកស្រាវជ្រាវបានរកឃើញថា មិនមានភាពខុសគ្នាខ្លាំងរវាងកម្រិតថ្នាក់សិក្សារបស់សិស្សនៅមធ្យមសិក្សាទុតិយភូមិឡើង។ ក្នុងនោះការបែងចែកថ្នាក់វិទ្យាសាស្រ្តពិត និងថ្នាក់វិទ្យាសាស្រ្តសង្គម ការសិក្សារបស់សិស្សនៅក្នុងការរីករាលដាលជំងឺកូវិដ-១៩ ការរីកចម្រើននៃបច្ចេកវិទ្យា អាចជាហេតុធ្វើឱ្យការសិក្សារបស់សិស្សនៅកម្រិតថ្នាក់ទី១០ ១១ និង១២មានកម្រិតប្រហាក់ប្រហែលគ្នា។

### ៤.៥.៣- ការរកឃើញចម្បង

តាមការវិភាគ បានរកឃើញថា ៖

- ការគ្រប់គ្រងពេលវេលាបានល្អជាកត្តាពន្យល់ពីអថេរភាគច្រើនដែលព្យាករណ៍ពីលទ្ធផលសិក្សារបស់សិស្សកាន់តែប្រសើរឡើង។ ទម្លាប់នៃការសិក្សាប្រកបដោយប្រសិទ្ធភាពតម្រូវឱ្យអ្នកសិក្សារៀបចេះចំតារាងពេលវេលាផ្ទាល់ខ្លួនសម្រាប់ខ្លួនពួកគេ ដោយបែងចែករយៈពេលជាក់លាក់មួយសម្រាប់មុខវិជ្ជារៀនរបស់ពួកគាត់ អាស្រ័យលើថាតើមុខវិជ្ជានីមួយៗមានភាពលំបាកប៉ុណ្ណា។
- សិស្សប្រុសនិងស្រីបានប្រើការប្រឡង កិច្ចការផ្ទះ ការអាន និងការកត់ចំណាំ ការផ្តោតអារម្មណ៍ និងការប្រើប្រាស់ពេលវេលាទាក់ទងនឹងទម្លាប់សិក្សាបានប្រហាក់ប្រហែលគ្នា ។
- សិស្សដែលសិក្សាតាមកម្រិតថ្នាក់ទី១០ ១១ និង១២បង្កើតទម្លាប់សិក្សាការប្រឡង កិច្ចការផ្ទះ ការអាន និងការកត់ចំណាំ ការផ្តោតអារម្មណ៍ និងការប្រើប្រាស់ពេលវេលាទាក់ទងនឹងទម្លាប់សិក្សាបានប្រហាក់ប្រហែលគ្នា។

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១- សេចក្តីសន្និដ្ឋាន

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទ ស្តីពីឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សលើលទ្ធផលរៀនសូត្រនៅមធ្យមសិក្សាទុតិយភូមិ ករណីសិក្សានៅខេត្តត្បូងឃ្មុំ បានបង្ហាញឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់សិស្សមធ្យមសិក្សាទុតិយភូមិ នៅខេត្តត្បូងឃ្មុំ ស្ថិតនៅកម្រិតល្អតាមរយៈតម្លៃមធ្យមដែលខ្ពស់ និងចំណុចដែលគួរកែលម្អបន្ថែម(តម្លៃមធ្យមទាបជាងគេ) ដើម្បីឱ្យសិស្សមានទម្លាប់សិក្សាកាន់តែល្អប្រសើរ។ ខាងក្រោមនេះជាចំណុចសំខាន់បី តាមរយៈលទ្ធផលដែលបានបង្ហាញក្នុងការសិក្សាស្រាវជ្រាវនេះ គឺទី១_ទម្លាប់សិក្សារបស់សិស្សជះឥទ្ធិពលលើលទ្ធផលរៀនសូត្របានតម្លៃមធ្យមខ្ពស់ ទី២_ទម្លាប់សិក្សារបស់សិស្សជះឥទ្ធិពលលើលទ្ធផលរៀនសូត្របានតម្លៃមធ្យមទាប ទី៣_ប្រៀបធៀបឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេផ្អែកតាមភេទ និងកម្រិតថ្នាក់។

1) ទម្លាប់សិក្សារបស់សិស្សជះឥទ្ធិពលលើលទ្ធផលរៀនសូត្របានតម្លៃមធ្យមខ្ពស់ ដែលបង្ហាញពីការអនុវត្តបានល្អ ៖

សម្រាប់សិស្សមានទម្លាប់ការលើការសិក្សារបស់ខ្លួនបានល្អ គួរជាទីមោទនៈដែលទម្លាប់ទាំងអស់នោះមានជាអាទិ៍៖ ការអាន និងការធ្វើកំណត់ត្រា ការផ្តោតអារម្មណ៍ កិច្ចការផ្ទះ ការប្រឡង។ នេះមានន័យថាសិស្សមានសមត្ថភាពក្នុងការផ្តោតអារម្មណ៍ក្នុងការសិក្សា ដោយមិនមានសំឡេងរំខានពីកត្តាខាងក្រៅ ឬបរិយាកាសមិនល្អ ក្នុងនោះផងដែរសិស្សអាចធ្វើកំណត់ត្រាពីអត្ថបទដែលពួកគេមានអាន ជាកថាខណ្ឌតូចៗងាយស្រួលក្នុងការស្វែងយល់អត្ថន័យក្នុងអត្ថបទ និងងាយធ្វើការចង់ចាំ។ សិស្សបានប្រឹងប្រែងធ្វើកិច្ចការផ្ទះដែលគ្រូបានដាក់ឱ្យ ដោយមិនត្រូវការជំនួយពីអ្នកដទៃ ក្រោយពេលចេញពីថ្នាក់រៀន និងបានប្រគល់ជូនគ្រូពិនិត្យវិញទាន់ពេលវេលា បង្ហាញពីការយកចិត្តរបស់ពួកគេក្នុងការធ្វើស្វ័យសិក្សានៅផ្ទះចំពោះមេរៀនដែលមានសិស្សរួចហើយ និងស្វែងរកចំណេះថ្មីបន្ថែម និងពួកគេបានត្រៀមខ្លួនបានយ៉ាងល្អ

ក្នុងការប្រឡង ដោយព្យាយាមគិតយ៉ាងមត់ចត មិនមានអារម្មណ៍ភិតភ័យ និងបានបញ្ចប់ការប្រឡងតាមពេលវេលាកំណត់។

2) ទម្លាប់សិក្សារបស់សិស្សជះឥទ្ធិពលលើលទ្ធផលរៀនសូត្របានតម្លៃមធ្យមខ្ពស់ ដែលបង្ហាញពីការអនុវត្តបានកម្រិតមធ្យមគឺៈ

ការគ្រប់គ្រងពេលវេលា តាមរយៈការឆ្លើយតប របស់គ្រូ និងសិស្សបានលើកឡើងថា ការគ្រប់គ្រងពេលវេលាក្នុងការសិក្សារបស់សិស្សមិនទាន់បានល្អប្រសើរនៅឡើយទេ។ នេះបង្ហាញថាសិក្សាមិនទាន់ធ្វើបានល្អលើការប្រើប្រាស់ពេលវេលា ក្នុងការកំណត់ផែនការសកម្មភាពជាប្រចាំជាមុន សម្រាប់ម៉ោងដែលត្រូវសិក្សាលើមុខវិជ្ជាសិក្សារបស់ពួកគេដោយពួកគេបានចំណាយពេលវេលាជាច្រើនលើកិច្ចការផ្សេងទៀត។

3) ការប្រៀបធៀបឥទ្ធិពលនៃទម្លាប់សិក្សារបស់សិស្សដែលជះលើលទ្ធផលរៀនសូត្ររបស់ពួកគេផ្អែកតាមភេទ និងកម្រិតថ្នាក់ បង្ហាញថាមិនមានទំនាក់ទំនងយ៉ាងសំខាន់រវាងភេទ និងកម្រិតថ្នាក់និងទម្លាប់សិក្សារបស់សិស្ស។ ចំពោះការប្រៀបធៀបលើភេទយើងឃើញថា សិស្សប្រុស និងសិស្សស្រីមានទម្លាប់សិស្សប្រហាក់ប្រហែលគ្នា ផ្អែកលើស្ថិតិយ៉ាងមានសារៈសំខាន់ក្នុងកម្រិត *P >0.0៥ ។ នេះមានន័យថាសិស្សប្រុសនិងសិស្សស្រីមានការអនុវត្តទម្លាប់សិក្សាប្រហាក់ប្រហែលគ្នា ទោះបីជាភេទទាំងពីរនេះ ខុសគ្នាក៏ដោយដែលវាបង្ហាញពីសមភាពក្នុងការទទួលបានសេវាអប់រំ ការប្រើប្រាស់ពេលវេលាក្នុងសិក្សាបានដូចគ្នា។ រីឯការប្រៀបធៀបលើកម្រិតថ្នាក់សិក្សាថ្នាក់ទី១០ ១១ និង១២មិនមានភាពខុសប្លែកគ្នាលើតម្លៃមធ្យមពិន្ទុសម្រាប់ថ្នាក់ទាំងបីកម្រិតលើរិមាត្រនៃទម្លាប់សិក្សារបស់ពួកគេ។ កត្តានេះអាចបណ្តាលមកពីការបែងចែកថ្នាក់វិទ្យាសាស្ត្រពិត និងថ្នាក់វិទ្យាសាស្ត្រសង្គម ការសិក្សារបស់សិស្សនៅក្នុងសម័យកាលរីករាលដាលជំងឺកូវីដ-១៩ និងការរីកចម្រើននៃបច្ចេកវិទ្យា។

ជារួមទម្លាប់សិក្សាមានទំនាក់ទំនងយ៉ាងសំខាន់ទៅនឹងលទ្ធផលសិក្សារបស់សិស្ស។ ដូច្នេះការបង្កើតទម្លាប់សិក្សាប្រកបដោយប្រសិទ្ធភាពចំពោះសិស្ស គឺជាលទ្ធផលនៃកម្មវិធីណែនាំ និងប្រឹក្សាដ៏ល្អរបស់គ្រូ។ សិស្សដែលត្រូវបានណែនាំ និងការប្រឹក្សាបានល្អគឺត្រូវបានតម្រង់ទិសលទ្ធផល ដូច្នេះហើយពួកគេនឹងធ្វើបានល្អក្នុងការប្រឡង។ ក្នុងនោះផងដែរ ការរកឃើញនេះបង្ហាញថា ទម្លាប់សិក្សាកាន់តែល្អ

លទ្ធផលសិក្សារបស់សិស្សកាន់តែខ្ពស់ រីឯទម្លាប់សិក្សាមិនល្អនឹងធ្វើឱ្យលទ្ធផលសិក្សាមិនបានកម្រិតខ្ពស់។ ការបង្កើតទម្លាប់សិក្សាប្រកបដោយប្រសិទ្ធភាពនឹងបង្កើតការយល់ដឹងសម្រាប់ការរៀនទៀងទាត់ និងមានស្ថិរភាព។ ដើម្បីជួយសិស្សឱ្យធ្វើបានប្រសើរឡើងលើការអនុវត្តការសិក្សារបស់ពួកគេ វាជាការសំខាន់ណាស់ដែលអ្នកប្រឹក្សាផ្តល់ការពិចារណាលើការស្រាវជ្រាវឱ្យបានគ្រប់គ្រាន់ចំពោះទម្លាប់សិក្សារបស់សិស្ស។ ការប្រឹក្សាសម្រាប់ទាំងអស់គ្នា ហើយសិស្សវិទ្យាល័យគឺជាមនុស្សម្នាក់ដែលត្រូវការការប្រឹក្សាផងដែរ។ ក្នុងនោះផងដែរអ្នកចិត្តសាស្ត្រដែលប្រឹក្សាគួរផ្តល់ការយកចិត្តទុកដាក់លើការស្រាវជ្រាវស៊ីជម្រៅចំពោះតួនាទីសំខាន់នៃកត្តាផ្ទាល់ខ្លួនរបស់សិស្សនៅក្នុងការអនុវត្តការសិក្សារបស់ពួកគេ និងផ្តល់ការយល់ដឹងពីទម្លាប់សិក្សារបស់សិស្ស ទាក់ទងនឹងកិច្ចការផ្ទះ និងការចាត់ចែង ពេលវេលាដែលបានបែងចែកសម្រាប់ការសិក្សា ការអាន និងការកត់ត្រា និងការផ្តោតអារម្មណ៍ ។

## ៥.២- សំណូមពរ

ផ្អែកលើការសិក្សាស្រាវជ្រាវខាងលើ អ្នកស្រាវជ្រាវសូមលើកជាសំណូមពរមួយចំនួនទៅកាន់ភាគីពាក់ព័ន្ធទាំងអស់ក្នុងវិស័យអប់រំ ដូចជាមាតាបិតា គ្រូបង្រៀន និងរដ្ឋាភិបាលក្នុងការលើកទឹកចិត្តសិស្សានុសិស្សក្នុងផ្នែកនៃទំនួលខុសត្រូវរៀងៗខ្លួន ដូចជាការផ្តល់សម្ភារៈសិក្សា ទីកន្លែងសិក្សា ទទួលស្គាល់ឧត្តមភាព ការកោតសរសើរដល់សិស្សានុសិស្សដែល ខិតខំប្រឹងប្រែង ឱ្យបានឆាប់តាមដែលអាចធ្វើបាន។ទាំងនេះនឹងជួយជំរុញទឹកចិត្តសិស្សឱ្យឆ្ពោះទៅរកការសិក្សាជាវិជ្ជមាន។

ក) ក្រសួងអប់រំ យុវជន និងកីឡា

ក្រសួងអប់រំ យុវជន និងកីឡាបណ្តុះបណ្តាលអ្នកប្រឹក្សាគរុកោសល្យបន្ថែម ហើយឱ្យពួកគាត់បានចូលបម្រើនៅវិទ្យាល័យ ដើម្បីជាជំនួយដល់សិស្សានុសិស្ស និងលោកគ្រូអ្នកគ្រូ។ ក្នុងនោះផងដែរ គ្រប់សូចនាករនៃទម្លាប់សិក្សា (ដូចជាកិច្ចការផ្ទះ និងកិច្ចការដែលទាក់ទងនឹងការផ្តោតអារម្មណ៍ ការគ្រប់គ្រងពេលវេលា ទាក់ទងនឹងការអាន និងការកត់ចំណាំ និងទាក់ទងនឹងការប្រឡង) គួរតែត្រូវបានផ្តល់ការពិចារណានៅពេលរៀបចំគោនយោបាយអប់រំណាមួយសម្រាប់សិស្សវិទ្យាល័យ។

ខ) សម្រាប់សាលារៀន

សម្រាប់គណៈគ្រប់គ្រងសាលារៀនៈពង្រឹងការលើកទឹកចិត្តគ្រូនិងសិស្សតាមដែលអាចធ្វើទៅបាន។ ជានាបាននូវ ស្វ័យភាព និងគណនេយ្យភាពសាលារៀន រៀបចំស្នើសុំពីភាគីពាក់ព័ន្ធលើដំណើរការសិក្សារបស់សិស្ស ពិសេសបង្កើតបណ្ណាល័យសម្រាប់សិស្សអានសៀវភៅ និងជម្រុយសូចនាករនៃទម្លាប់សិក្សារបស់សិស្សទាំងប្រាំនេះ ឱ្យកាន់តែល្អប្រសើរឡើង។

សម្រាប់លោកគ្រូអ្នកគ្រូៈ ចាំបាច់ណាស់ក្នុងការរក្សាទំនាក់ទំនងដ៏ល្អ និងស្និទ្ធស្នាលជាមួយសិស្ស ព្រោះនេះជាវិធីសាស្រ្តងាយស្រួលរបស់គ្រូក្នុងការដោះស្រាយបញ្ហាសិក្សារបស់សិស្ស និងត្រូវខិតខំធ្វើជាគំរូល្អដល់សិស្ស។ ការលើកឡើងទាំងនេះអាចសម្រេចបានដោយការរៀបចំប្រឹក្សាជាក្រុមត្រូវបានរៀបចំសម្រាប់សិស្សអំពីទម្លាប់សិក្សាល្អ និងសមភាពយេនឌ័រផងដែរ។ ក្នុងនោះផងសិស្សគួរតែត្រូវបានបង្រៀនជំនាញសិក្សាដើម្បីឱ្យពួកគេអាចបណ្តុះជំនាញសិក្សាបានល្អ និងមានប្រសិទ្ធភាព។

គ) មាតាបិតាសិស្ស និងសហគមន៍

មាតាបិតាគួរកែលម្អកម្រិតនៃការគ្រប់គ្រង និងការថែទាំកូនរបស់ពួកគេ ដោយបង្ហាញការចាប់អារម្មណ៍ និងការព្រួយបារម្ភបន្ថែមទៀតនៅក្នុងការងារសិក្សារបស់កូន តាមរយៈការផ្តល់បរិយាកាសអំណោយផលសម្រាប់ការសិក្សា ការផ្តល់សម្ភារៈសម្រាប់ការសិក្សា និងការជួយជ្រោមជ្រែងសព្វបែបយ៉ាងក្នុងការសិក្សារបស់ពួកគេ។

ឃ) ការណែនាំសម្រាប់ការស្រាវជ្រាវបន្ត

